# រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

# របាយការណ៍ បូកសរុបការងារ ឆ្នាំ ២០១៨ និងទិសដៅ ឆ្នាំ ២០១៩





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច

# របាយការណ៍
# បូកសរុបលទ្ធផលការងារឆ្នាំ២០១៨
# និងទិសដៅឆ្នាំ២០១៩
# របស់
# ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
# និងអធិការកិច្ច

ឆ្នាំ ២០១៩

# មាតិកា

ក. សេចក្តីផ្តើម ..... 1
ខ. សមិទ្ធផលការងារ ..... 1
១. រដ្ឋបាលកិច្ចការទូទៅ ..... 1
១.១. រដ្ឋបាល ..... 1
១.២. បុគ្គលិក និងធនធានមនុស្ស ..... 2
១.៣. ការបណ្តុះបណ្តាល ..... 3
១.៤. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ..... 3
១.៥. ផែនការ និងស្ថិតិ ..... 4
១.៦. សហប្រតិបត្តិការអន្តរជាតិ ..... 5
២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ..... 6
២.១. នីតិកម្ម ..... 6
២.២. ការអប់រំ ផ្សព្វផ្សាយច្បាប់ ..... 6
២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ..... 7
២.៤. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ..... 7
២.៥. ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ..... 7
៣. អធិការកិច្ច ..... 8
៣.១. អធិការកិច្ច ..... 8
៣.២. ការតាមដានការអនុវត្តច្បាប់ ..... 10
៣.៣. ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ..... 12
៤. វិទ្យាស្ថានជាតិអធិការកិច្ច ..... 13
៥. សវនកម្មផ្ទៃក្នុង ..... 14
៦. ការងារផ្សេងទៀត ..... 15
៦.១ យេនឌ័រ ..... 15
៦.២. ការចងសម្ព័ន្ធមេត្រីភាព ..... 17
៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន ..... 17
៦.៤. អ្នកនាំពាក្យក្រសួង ..... 17
គ. ការប្រឈម ..... 18
ឃ. ទិសដៅការងារបន្ត ..... 18
១.រដ្ឋបាលកិច្ចការទូទៅ ..... 19
១.១. រដ្ឋបាល ..... 19
១.២. បុគ្គលិក និងធនធានមនុស្ស ..... 19

១.៣. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ .......... 19
១.៤. ផែនការ និងស្ថិតិ .......... 20
១.៥. សហប្រតិបត្តិការអន្តរជាតិ .......... 20
២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា .......... 21
២.១. នីតិកម្ម .......... 21
២.២. ការអប់រំផ្សព្វផ្សាយច្បាប់ .......... 21
២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា .......... 21
៣. អធិការកិច្ច .......... 21
៣.១. អធិការកិច្ច .......... 21
៣-២-ការតាមដានការអនុវត្តច្បាប់ .......... 22
៣-៣-ការទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ .......... 22
៤. វិទ្យាស្ថានជាតិអធិការកិច្ច .......... 22
៥. សវនកម្មផ្ទៃក្នុង .......... 23
៦. ការងារផ្សេងទៀត .......... 23
៦.១. យេនឌ័រ .......... 23
៦.២. ការចងសម្ព័ន្ធមេត្រីភាព .......... 24
៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន .......... 24
៦.៤. អ្នកនាំពាក្យក្រសួង .......... 24
**ខ. សេចក្ដីសន្និដ្ឋាន** .......... 24
**ឧបសម្ព័ន្ធ ទី ១. កម្មវិធីសន្និបាត** .......... 27
**ឧបសម្ព័ន្ធ ទី ២. របាយការណ៍សង្ខេបលទ្ធផលការងារ ២០១៨និងទិសដៅ ២០១៩** .......... 30
**ឧបសម្ព័ន្ធ ទី ៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាត** .......... 44
**ឧបសម្ព័ន្ធទី ៤. សុន្ទរកថាបើកសន្និបាត** .......... 47
**ឧបសម្ព័ន្ធទី ៥. សុន្ទរកថាបិទសន្និបាត** .......... 52

# ក. សេចក្តីផ្តើម

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខ ព្រះរាជាណាចក្រកម្ពុជាទទួលបានសុខ សន្តិភាព កិត្យានុភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។ កម្ពុជាដែលធ្លាប់តែជាសមរភូមិនៃការប្រទាញប្រទង់ពីសំណាក់មហាអំណាច និងជាប្រទេសដែលពោរពេញទៅដោយសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ជាវាលពិឃាដ នៃរបបប្រល័យពូជសាសន៍បានប្រែក្លាយទៅជាទីផ្សារវិនិយោគ ដ៏ទាក់ទាញ ជាម្ចាស់ណីយដ្ឋាន និងទីផ្សារទេសចរណ៍ដ៏ល្បីល្បាញលំដាប់ពិភពលោក និងជាប្រទេសមួយមានមោទនភាពជាតិស្មើមុខស្មើមាត់ជាមួយប្រទេសដ៏ទៃលើពិភពលោក។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្រ្តរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាបានបានប្រកាន់យករបបនយោបាយប្រជាធិបតេយ្យ ពហុបក្ស និងរបបសេដ្ឋកិច្ចបែបទីផ្សារសេរី និងបើកចំហរ ដោយធ្វើការកែទម្រង់ស៊ីជម្រៅ និងដាក់ចេញយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងពិភពលោក។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការងារចំបង គឺការធ្វើទំនាក់ទំនងសម្របសម្រួលការងាររវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ច លើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និង បាតុភាពអសកម្មនានាដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធរបស់ប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ក្នុងឆ្នាំ២០១៨ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានសម្រេចនូវសមិទ្ធផលនានា ជាច្រើនដូចរៀបរាប់ខាងក្រោម។

# ខ. សមិទ្ធផលការងារ

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១.១. រដ្ឋបាល

នាយកដ្ឋានរដ្ឋបាលបានបំពេញការងារ ដូចខាងក្រោម៖

-ទទួលលិខិតចូលពីក្រសួង ស្ថាប័ននានាចំនួន១២៧៤ ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១៩០២ ច្បាប់។

-គ្រប់គ្រងចរាចរល់ឯកសារចេញ-ចូលក្រសួង និងរៀបចំតម្កល់ទុកឯកសារ។

-រៀបចំតាំងបដាពាក្យស្លោកគ្រប់ពិធីបុណ្យជាតិ-អន្តរជាតិ។

-គ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-រៀបចំសារលិខិតថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច**ព្រះនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងធ្វើសារលិខិតជូនពរថ្នាក់ដឹកនាំជាន់ខ្ពស់របស់ជាតិ។

-ធ្វើសេចក្តីសម្រេច សេចក្តីជូនដំណឹង លិខិតបង្គាប់ការ លិខិតអញ្ជើញ វិញ្ញាបនបត្ររដ្ឋបាល អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ និងលិខិតរដ្ឋបាលផ្សេងៗ បញ្ជូនទៅក្រសួង ស្ថាប័ននានា។

-រៀបចំសម្របសម្រួល និងចូលរួមកិច្ចប្រជុំរបស់ក្រសួងគ្រប់កម្មពិធីជួបសវនាការការងាររវាងថ្នាក់ដឹកនាំក្រសួងជាមួយភ្ញៀវជាតិ-អន្តរជាតិ។

-ចុះពង្រឹងការងាររដ្ឋបាល នៅគ្រប់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី ខេត្ត។

-បូកសរុបរបាយការណ៍ របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំសម្រាប់ជូនទីស្តីការគណៈរដ្ឋមន្ត្រី។

-ចុះរៀបចំកម្មវិធី និងអមដំណើរជាមួយថ្នាក់ដឹកនាំក្រសួង ដូចជាសិក្ខាសាលា ការចុះសួរសុខទុក្ខកងកម្លាំងការពារព្រំដែនកម្ពុជា-ថៃ ពិធីប្រកាសចូលកាន់មុខតំណែងប្រធានមន្ទីរ និងពិធីបុណ្យជាតិនៅតាមបណ្តា រាជធានី ខេត្តមួយចំនួន។

-ចូលរួមទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បណ្តាប្រទេសនានា ដែលមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា។

## ១.២. បុគ្គលិក និងធនធានមនុស្ស

នាយកដ្ឋានបុគ្គលិក និងធនធានមនុស្សបានបំពេញការងារ ដូចខាងក្រោមៈ

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសកម្មភាពជនពិការ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើប្រកាសស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន៤៨ រូប។

-ធ្វើប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន៦រូប ពីក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យទៅបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈចំនួន១រូប និងក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួន៥រូប។

-ធ្វើប្រកាសស្តីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការចំនួន៤រូបពីក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន១រូប ក្រសួងមហាផ្ទៃចំនួន១រូប ក្រសួងរ៉ែ និងថាមពលចំនួន១រូប និងក្រសួងវប្បធម៌

និងវិចិត្រសិល្បៈ ចំនួន១រូប ឱ្យមកបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើប្រកាសស្ដីពីការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការថ្មីចំនួន ៦៦រូប ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងដាក់ឱ្យធ្វើកម្មសិក្សាសាកល្បងក្នុងក្របខ័ណ្ឌរយៈពេល១២ខែ។

-ធ្វើប្រកាសស្ដីពីការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន២រូប ពីមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ធំឱ្យទៅបម្រើការងារនៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តព្រះវិហារ និងពីនាយកដ្ឋានទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ ឱ្យទៅបម្រើការងារនៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកណ្ដាល។

-ធ្វើប្រកាសស្ដីពីការលុបឈ្មោះ និងក្របខ័ណ្ឌមន្ត្រីរាជការចំនួន១រូប ដែលទទួលមរណភាព។

-ធ្វើប្រកាសស្ដីពីការផ្លាស់ប្ដូរមន្ត្រីជាប់កិច្ចសន្យាចំនួន២០រូប នៅទីស្ដីការក្រសួង។

-ធ្វើប្រកាសស្ដីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចំនួន១រូប ចូលបម្រើការងារវិញ។

## ១.៣. ការបណ្តុះបណ្តាល

ក្រសួងចាត់បញ្ជូនមន្ត្រីរាជការចំនួន១០៩រូប ទៅបណ្ដុះបណ្ដាលជំនាញផ្សេងៗ នៅក្នុងប្រទេស និងក្រៅប្រទេស ក្នុងនោះចំនួន២០រូប ជំនាញអធិការកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងចំនួន៣រូបជំនាញ ភាសាចិន នៅសាធារណរដ្ឋប្រជាមានិតចិន។

## ១.៤. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់

ក្រសួងបានបំពេញការងារដូចខាងក្រោម៖

-ទាក់ទងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។

-កែសម្រួលក្រុមការងារកែទម្រង់ ហិរញ្ញវត្ថុសាធារណៈ និងបង្កើតលេខាធិការដ្ឋាន នៃក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្រសួង។ ក្រុមការងារបានបំពេញភារកិច្ចយ៉ាងសកម្ម ជាពិសេសក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលេខាធិការដ្ឋាន នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើការជាមួយក្រុមការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដែលប្រព័ន្ធនោះនឹងត្រូវតម្លើងនៅក្រសួងនៅឆ្នាំ២០២០។

-ក្រុមការងារកែទម្រង់ ហិរញ្ញវត្ថុសាធារណៈរួមនឹងថ្នាក់ដឹកនាំ អង្គភាពថវិកាទាំងអស់ក្នុងក្រសួងបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងការណែនាំសម្រាប់អនាគត ដែលធ្វើបទបង្ហាញ និងឆ្លើយសំណួរ ដោយក្រុមការងារមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ក្រសួងបានប្រជុំពិភាក្សា និងចេញសេចក្ដីជូនដំណឹងទៅថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ពីការចាប់ផ្ដើមផ្ដល់ប្រាក់បេសកកម្ម និងលាភការផ្សេងៗ តាមរយៈបញ្ចូលទៅក្នុងគណនីសាមីជន ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២០ តទៅ។

-រៀបចំរបាយការណ៍ប្រៀបធៀបផែនការចំណាយ តាមកម្មវិធីប្រចាំត្រីមាស និងការអនុវត្តជាក់ស្តែង ដោយឆ្លុះបញ្ចាំងគោលដៅចំណាយក្នុងត្រីមាសនីមួយៗ។

-ក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈបានជួបពិភាក្សាការងារ ជាមួយអគ្គលេខាធិការរង នៃអគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួង។

-បង្កើតក្រុមការងារប្រព័ន្ធ FMIS ប្រចាំក្រសួងដើម្បីងាយស្រួលទំនាក់ទំនង ការងារជាមួយក្រុមការងារ FMIS នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំ និងប្រមូលធាតុចូលសម្រាប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបញ្ជី សារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៨។

-ផ្សព្វផ្សាយព័ត៌មាន ស្តីពីលទ្ធកម្មសាធារណៈតាមរយៈកាសែត បានផ្សព្វផ្សាយកិច្ច លទ្ធកម្មសាធារណៈដល់អ្នកដេញថ្លៃនិងក្រុមលទ្ធកម្មត្រៀមអនុវត្តសេចក្តីជូននិងសារាចរណែនាំស្តីពីការត្រៀមរៀបចំផែនការ យុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។

## ១.៥. ផែនការ និងស្ថិតិ

ក្រសួងបានបំពេញការងារដូចខាងក្រោម៖

-រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០១៩-២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើទៅក្រសួងផែនការរួមមាន៖ (១) ការសាងសង់អគារទីស្តីការក្រសួង និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត (២) ការសិក្សាបឋមស្តីពីការផ្សព្វផ្សាយច្បាប់អាទិភាពទាំង១១ (៣) ការកសាងច្បាប់អធិការកិច្ច (៤) ការងារតាមដានការអនុវត្តច្បាប់ (៥) កិច្ចដំណើរការវេទិកាសាធារណៈនៅតាមមូលដ្ឋាន (៦) ការស្ទាបស្ទង់មតិអំពីតម្រូវការ និងកង្វល់របស់ប្រជាពលរដ្ឋ (៧) កម្មវិធីបណ្តុះបណ្តាលជំនាញការងារអធិការកិច្ច (៨) បានចុះណែនាំលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ រដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្ត នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងចូលរួមប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសចំនួន២លើក និងកម្រិតនយោបាយចំនួន១លើក។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកា២០១៩-២០២១ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញ២៥ រាជធានី-ខេត្ត នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-រៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំ២០១៩ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញ២៥ រាជធានី-ខេត្ត នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបានចូលរួមកិច្ចប្រជុំចរចារកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំក្រសួង និងក្រសួង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ (ផយអជ) ផ្ញើជូនក្រសួងផែនការ។

-រៀបចំសេចក្តីព្រាងផែនការសកម្មភាព ស្តីពីការអប់រំផ្សព្វផ្សាយច្បាប់ឆ្នាំ២០១៩-២០២១ សម្រាប់ជាធាតុចូលរួមចំណែកអនុវត្ត នៃគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០។

-រៀបចំរបាយការណ៍វឌ្ឍនភាព ស្តីពីការងារអប់រំផ្សព្វផ្សាយច្បាប់ឆ្នាំ២០១៧ រួមចំណែកអនុវត្តគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ ផ្ញើជូនក្រសួងផែនការ។

-រៀបចំរបាយការណ៍ស្តីពីស្ថិតិផ្លូវការមានការចាត់តាំងរួមមាន៖ ការអនុម័តច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ផ្ញើជូនក្រសួងផែនការ។

-រៀបចំសៀវភៅស្ថិតិទូទៅសម្រាប់ក្រសួង ដែលមានបញ្ជីរាយនាមមន្ត្រីរាជការ និងថ្នាក់ដឹកនាំក្រសួង ព្រមទាំងមន្ទីរជំនាញរាជធានី-ខេត្តទាំង២៥ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច (មិនទាន់បានបញ្ចប់នៅឡើយ)។

-ប្រមូល និងបញ្ចូលទិន្នន័យតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ តាមអគ្គនាយកដ្ឋានទាំង៣ នៃទីស្តីការក្រសួង និងតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ រវាងអ្នកប្រើប្រាស់ទិន្នន័យ អំពីការរៀបចំតារាងអាទិភាពរបស់ជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

-ចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ក្រោមការរៀបចំរបស់ក្រសួងផែនការ។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួង កម្រិតបច្ចេកទេស លើសេចក្តីព្រាងផែនការសកម្មភាព ២០១៩-២០២១ នៃគោលនយោបាយជាតិប្រជាជន២០១៦-២០៣០ នៅភោជនីយដ្ឋានទន្លេបាសាក់២ និងសណ្ឋាគារកាំបូឌីយ៉ាណា។

-ចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស លើការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈសម្រាប់មន្ត្រីគ្រប់គ្រង ហិរញ្ញវត្ថុ និងមន្ត្រីគ្រប់គ្រងថវិកា។

-បន្តកែសម្រួលធាតុចូលសម្រាប់រៀបចំសេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០១៩-២០២១ នៃគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០។

-បន្តសម្របសម្រួលការងាររៀបចំផែនការជាមួយមន្ត្រីជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១.៦. សហប្រតិបត្តិការអន្តរជាតិ

ក្រសួងបានសម្រេចការងារដូចខាងក្រោម៖

-ថ្នាក់ដឹកនាំក្រសួងបានទទួលជួបសវនាការការងារជាមួយ ១) លោកជំទាវ **ម៉ានីកា ចេន** (Manika Jain) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ២) ឯកឧត្តម **វូ ក្វាងមិញ** (Vu Quang Minh) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា ៣) ឯកឧត្តម **ហ៊្សុង ប៉ី** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានបញ្ចប់អាណត្តិការទូតនៅកម្ពុជា ៤) គណៈប្រតិភូ អាជ្ញាធរអធិការកិច្ចរដ្ឋ និងប្រឆាំងអំពើពុករលួយ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៥) គណៈប្រតិភូដែលដឹកនាំដោយឯកឧត្តមបណ្ឌិត **ខាំផេង សាយស៊ុំផេង** រដ្ឋមន្ត្រីក្រសួងការងារ និងសុខុមាលភាពសង្គម នៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ៦) គណៈប្រតិភូសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ដឹកនាំដោយឯកឧត្តម **ហាវ អាឡេញ** (HAV A LENH) អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការរណសិរ្សមាតុភូមិវៀតណាម ៦) ឯកឧត្តម **ប៉ាន់យ៉ារ៉ាក់ ភូនធប់** (Panyarak PoonThup) ឯកអគ្គរាជទូត

វិសោមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃ ៧) លោក **អេដវើដ វីលសឹន** (EDWARD WILSON) ចៅហ្វាយក្រុង SIGNAL HILL សហរដ្ឋអាមេរិក ៨) ឯកឧត្តម **ហើ ជុនគើ** (HE JUNKE) ប្រធានសហព័ន្ធយុវជន ទូទាំងប្រទេសចិន និង ៩) គណៈប្រតិភូសមាគមមិត្តភាពវៀតណាម-កម្ពុជា ដឹកនាំដោយលោក **ង៉ុ ម៉ៅ** ប្រធានសមាគម នៅទីស្តីការក្រសួង។

-អញ្ជើញឯកអគ្គរដ្ឋទូត សាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិតសភាកម្ពុជាដើម្បីចូលរួមពិធីប្រគល់វិញ្ញាបនបត្រដល់សិក្ខាកាមជាមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានរៀនភាសាចិនកម្រិតបឋម។

-ចាត់បញ្ជូនគណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចដឹកនាំដោយឯកឧត្តម **ប៉ែន ច័ន្ទសុខរិន** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ចូលរួមប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាមលើកទី១៦ (JC) នៅទីក្រុងហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ចាត់បញ្ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២០ រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចរយៈពេល១ខែ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ឯកឧត្តម **ប៉ែន ច័ន្ទសុខរិន** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ចូលរួមទស្សនកិច្ចសិក្សាស្វែងយល់ពីបទពិសោធន៍ក្នុងការផ្តល់សេវាសាធារណៈ នៅវិទ្យាស្ថានបណ្តុះបណ្តាលមន្ត្រីរាជការ របស់ប្រទេសសិង្ហបុរី។

# ២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

## ២.១. នីតិកម្ម

នាយកដ្ឋាននីតិកម្មបានសម្រេចការងារដូចខាងក្រោម៖

-បានចូលរួមរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន១១លើក។

-បានចូលរួមរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធាន និងនីតិវិធី នៃអធិការកិច្ចហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន៤លើក។

-បានចូលរួមកិច្ចប្រជុំអន្តរក្រសួងចំនួន៤លើក។

-បានចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណីស្តីពីកាតព្វកិច្ចចំនួន១លើក

-បានចុះស្ទង់មតិប្រជាពលរដ្ឋស្តីពីការយល់ដឹងលើច្បាប់ភូមិបាលចំនួន១៤លើក គឺខេត្តស្វាយរៀងចំនួន៤លើក ពោធិ៍សាត់ចំនួន២លើក សៀមរាបចំនួន២លើក កំពង់ធំចំនួន២លើក ព្រះសីហនុចំនួន២លើក និងខេត្តកែបចំនួន២លើក ដោយមានប្រជាពលរដ្ឋចូលរួមចំនួន១ ៦៩៧នាក់ (ស្ត្រីចំនួន៩១៣នាក់)។

## ២.២. ការអប់រំ ផ្សព្វផ្សាយច្បាប់

នាយកដ្ឋានអប់រំ ផ្សព្វផ្សាយច្បាប់បានបំពេញការងារដូចខាងក្រោម៖

-ចុះផ្សព្វផ្សាយច្បាប់ចំនួន១២៧លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាចំនួន ២២លើក និងមន្ទីររាជធានី-ខេត្តចំនួន១០៥លើក) គឺ ១) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ៣) ច្បាប់ស្តីពីការបង្ការ និងការទប់ស្កាត់ការរីករាលដាលមេរោគ/ជំងឺអេដស៍ ៤) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និង ៥) ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង នៅខេត្តព្រះសីហនុចំនួន២១លើក ខេត្តស្វាយរៀងចំនួន១៦លើក ខេត្តព្រៃវែងចំនួន១១លើក ខេត្តស្ទឹងត្រែងចំនួន១០លើក ខេត្តកណ្តាលចំនួន៩លើក ខេត្តតាកែវចំនួន៩លើក ខេត្តកំពង់ស្ពឺចំនួន៨លើក ខេត្តកំពង់ចាមចំនួន៧លើក ខេត្តត្បូងឃ្មុំចំនួន៦លើក ខេត្តកំពង់ធំចំនួន៦លើក ខេត្តកំពតចំនួន៤លើក ខេត្តឧត្តរមានជ័យចំនួន៤លើក ខេត្តបាត់ដំបងចំនួន៣លើក ខេត្តកែបចំនួន ៣លើក ខេត្តសៀមរាបចំនួន៣លើក ខេត្តបន្ទាយមានជ័យចំនួន២លើក ខេត្តកំពតចំនួន២លើក ខេត្តមណ្ឌលគិរីចំនួន១លើក ខេត្តប៉ៃលិនចំនួន១លើក និងរាជធានីភ្នំពេញចំនួន១លើក ដោយមានអ្នកចូលរួមចំនួន៣៣ ៥៧៤នាក់ (ស្ត្រីចំនួន១៤ ២៦៥នាក់) និងបានទទួលសំណួរចំនួន២.៥៨៨សំណួរ ព្រមទាំងបានបកស្រាយ និងបំភ្លឺដល់ម្ចាស់សំណួរ។

-ចុះសិក្សាស្រាវជ្រាវអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋ មុនការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៅឃុំត្រពាំងរាំង និងឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរចំនួន៨៩នាក់ (ស្ត្រីចំនួន៤៥នាក់) ក្នុងនោះប្រជាពលរដ្ឋមានចំនួន៤ភូមិស្មើនឹង៨០នាក់ និងអាជ្ញាធរមានចំនួន៩នាក់។

## ២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

ក្រសួងបានចាត់តំណាងចូលរួមប្រជុំអន្តរក្រសួង នៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន១លើក សេចក្តីព្រាងច្បាប់ចំនួន១៥លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៥លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន១លើក។

## ២.៤. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា លើសេចក្តីស្នើច្បាប់ចំនួន១លើក សេចក្តីព្រាងច្បាប់ចំនួន ២០លើក ការបោះឆ្នោតជ្រើសតាំងចំនួន២លើក ព្រះរាជសារចំនួន២លើក របាយការណ៍របស់រដ្ឋសភាចំនួន ១លើក ការអនុម័តបទបញ្ជាផ្ទៃក្នុងរដ្ឋសភានីតិកាលទី៦ចំនួន ១លើក ចូលរួមអមដំណើរជាមួយគណៈកម្មការទី៦ចំនួន ១លើក និងចូលរួមអមដំណើរជាមួយគណៈកម្មការទី៨ចំនួន ១ លើក។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភាលើសេចក្តីព្រាងច្បាប់ចំនួន ១៦លើក។

## ២.៥. ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

ក្រសួងបានចាត់ក្រុមការងាររៀបចំវេទិកាសាធារណៈ ដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន ១០លើក ដែលក្នុងនោះនៅខេត្តកំពង់ចាមចំនួន២លើក នៅខេត្តពោធិ៍សាត់ចំនួន២លើក នៅខេត្តកំពង់ឆ្នាំងចំនួន២លើក នៅខេត្តព្រៃវែងចំនួន២លើក និងនៅខេត្តកំពង់ស្ពឺចំនួន២លើក ដោយមានអ្នកចូលរួមចំនួន២.២០៨នាក់ (ស្ត្រីចំនួន៨៥៨នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន៥៤២ សំណូមពរ។

# ៣. អធិការកិច្ច

## ៣.១. អធិការកិច្ច

ក្រសួងបានចុះធ្វើអធិការកិច្ចលើមុខព្រួញទាំងបី គឺ វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច ដោយផ្តោតលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៦ និង២០១៧ នៅក្រសួងចំនួន១៥ (វិស័យសេដ្ឋកិច្ចចំនួន ៧ក្រសួង វិស័យរដ្ឋបាលទូទៅចំនួន ៤ក្រសួង ស្ថាប័ន និងវិស័យសង្គមកិច្ចចំនួន ៤ក្រសួង) និងនៅតាមបណ្តារាជធានី ខេត្តសរុបចំនួន ៦៣៤មន្ទីរ អង្គភាព (វិស័យសេដ្ឋកិច្ចចំនួន ២៩៥មន្ទីរ អង្គភាព វិស័យរដ្ឋបាលទូទៅចំនួន ១៣២មន្ទីរ អង្គភាព និង វិស័យសង្គមកិច្ចចំនួន ២០៧មន្ទីរ អង្គភាព)។

បានធ្វើលិខិតជូនដំណឹងទៅក្រសួង ស្ថាប័ន ឱ្យជំរុញមន្ទីរ អង្គភាពក្រោមឱវាទដើម្បីកែលម្អចំណុច ខ្វះខាតចំនួន៥១លើក។ ក្រសួងបានទទួលលិខិតឆ្លើយតបចំនួន១៩លើក។

តាមរយៈការចុះធ្វើអធិការកិច្ចពិនិត្យឃើញថា ថ្នាក់ដឹកនាំក្រសួង មន្ទីរ អង្គភាព និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់បានខិតខំយកចិត្តទុកដាក់អនុវត្តនូវតួនាទី ភារកិច្ចរបស់ខ្លួន និងច្បាប់ លិខិតបទដ្ឋាន គតិយុត្តពាក់ព័ន្ធបានល្អប្រសើរប្រកបដោយប្រសិទ្ធភាព ព្រមទាំងបានយកចិត្តទុកដាក់បណ្តុះបណ្តាល ធនធានមនុស្ស លើគ្រប់ផ្នែក គ្រប់ជំនាញ ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ ស្របតាមយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣នៃរាជរដ្ឋាភិបាល។ ក្រៅពីនេះថ្នាក់ដឹកនាំក្រសួង មន្ទីរ អង្គភាពក៏បានខិតខំ កែលម្អនូវចំណុចខ្វះខាត ដែលគណៈប្រតិភូអធិការកិច្ចបានពិនិត្យឃើញ ក្នុងការិយបរិច្ឆេទកន្លងមក ហើយចំណុចដែលសេសសល់ត្រូវការពេលវេលាដើម្បីកែលម្អបន្ថែមទៀត។

ចំណុចអវិជ្ជមានមួយចំនួនដែលគណៈប្រតិភូអធិការកិច្ចបានពិនិត្យឃើញនិងជំរុញឱ្យកែលម្អរួមមាន៖

- **ការគ្រប់គ្រងរដ្ឋបាល**

ក្រសួង មន្ទីរ អង្គភាពមួយចំនួនមានចំណុចខ្វះខាតលើការងារគ្រប់គ្រងរដ្ឋបាលដូចខាងក្រោម ៖

-ការិយាល័យរដ្ឋបាលមួយចំនួនបានកត់ត្រាលេខលិខិតស្ទួន រំលង កត់ត្រាលេខលិខិតដោយពុំបាន បញ្ជាក់ខ្លឹមសារ និងពុំបានបិទបញ្ជីសៀវភៅចុះលេខលិខិតចេញ។

-ការគ្រប់គ្រងវត្តមានមន្ត្រីរាជការពុំទាន់បានហ្មត់ចត់។

-រចនាសម្ព័ន្ធចាត់តាំងរបស់មន្ទីរ នៃអង្គភាពមួយចំនួន នៅតាមការិយាល័យថ្នាក់មន្ទីរ ក៏ដូចជា ការិយាល័យ ថ្នាក់ស្រុកមានភាពខ្វះចន្លោះ ដោយការិយាល័យខ្លះពុំមានប្រធានដឹកនាំ ឬពុំមានមន្ត្រីបំរើ ការងារ ឬមានមន្ត្រី តិចតួចមិនសមស្របនឹងទំហំការងារ ដែលពុំស្របតាមប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់មន្ទីរខេត្ត ក្រុង។

-ការគ្រប់គ្រងយានដ្ឋានជួសជុល កែច្នៃ រថយន្ត នៅមានការខ្វះខាត ដោយយានដ្ឋានមួយចំនួន មិនបានសុំការអនុញ្ញាតអាជីវកម្ម។

-ការប្រកបអាជីវកម្មភោជនីយដ្ឋាន-អាហារដ្ឋានមួយចំនួន ពុំបានសុំលិខិតអនុញ្ញាតអាជីវកម្ម។

- **ការគ្រប់គ្រងហិរញ្ញវត្ថុ**

ក្រសួង មន្ទីរ អង្គភាពមួយចំនួនមានចំណុចខ្វះខាតលើការងារគ្រប់គ្រងហិរញ្ញវត្ថុដូចខាងក្រោម ៖

-ការប្រើប្រាស់ថវិការដ្ឋទេយ្យបុរេប្រទានពុំទាន់បានសមស្របតាមសារាចរណែនាំ។

-ភាពយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធចូលថវិការដ្ឋ។

-ក្រសួង មន្ទីរមួយចំនួនបានរក្សាទុកសាច់ប្រាក់លើសចំនួនកំណត់។

-ការដកចំណូលថវិការដ្ឋយកទៅប្រើប្រាស់ខុសគោលការណ៍ហិរញ្ញវត្ថុ។

-មន្ទីរ អង្គភាពប្រមូលចំណូលមួយចំនួន ពុំបានប្រើប្រាស់បង្កាន់ដៃទទួលប្រាក់ដែលមានទម្រង់ឯកភាព និងបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ការសាងសង់ ជួសជុលផ្លូវលំជនបទមួយចំនួនពុំសមស្រប និងត្រឹមត្រូវតាមគម្រោងដែលបានលើកឡើង។

-ការចុះកិច្ចសន្យា ទទួលការមួយចំនួន ដោយពុំមានលក្ខណៈសម្បត្តិសមស្របដែលអាចបំពេញការងារបានឡើយ។

-ការបញ្ចេញប្រេងឥន្ធនៈ និងសម្ភារការិយាល័យមួយចំនួន ពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

-ការចំណាយថវិការដ្ឋសម្រាប់ទូទាត់ការជួសជុលមធ្យោបាយដឹកជញ្ជូន និងបរិក្ខារបច្ចេកទេសមួយចំនួន ពុំបានបញ្ជាក់ពីអត្តសញ្ញាណ និងពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវ តាមនីតិវិធីហិរញ្ញវត្ថុ។

-ការទូទាត់ប្រាក់ឧបត្ថម្ភ ដល់អ្នកជំងឺមួយចំនួន ពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

-ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី ពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានត្រឹមត្រូវ។

-ស្ថាប័នរដ្ឋមួយចំនួនពុំទាន់បានចាត់វិធានការតឹងទារបំណុល។

- **ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

-ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ កើនឡើង ថយចុះប្រចាំឆ្នាំមួយចំនួន ពុំទាន់ពេលវេលា។

-មានភាពយឺតយ៉ាវក្នុងការស្នើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភណ្ឌ នូវទ្រព្យសម្បត្តិដែលចាស់ទ្រុឌទ្រោម ខូចគុណភាព ប្រើប្រាស់លែងកើត។

-ដីកម្មសិទ្ធរដ្ឋមួយចំនួនត្រូវបានប្រជាពលរដ្ឋចូលកាន់កាប់ ដោយខុសច្បាប់ពុំទាន់ត្រូវបានដោះស្រាយ។

-ក្រសួង មន្ទីរ អង្គភាពមួយចំនួន ពុំទាន់បានធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅឡើយ។

ក្នុងការងារទំនាក់ទំនង និងធ្វើអធិការកិច្ចឡើងវិញ ក្រសួងបានទទួលរបាយការណ៍ និងលិខិតជូនជ្រាបពីក្រសួងចំនួន៩គឺ៖ (១) ក្រសួងមុខងារសាធារណៈ ចំនួន៥១លើក (២) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន១៦លើក (៣) ក្រសួងការពារជាតិ ចំនួន១២លើក (៤) ក្រសួងមហាផ្ទៃ ចំនួន ១១លើក (៥) ក្រសួងធម្មការ និងសាសនា ចំនួន៦លើក (៦) ក្រសួងទេសចរណ៍ ចំនួន៥លើក (៧) ក្រសួងអប់រំ យុវជន និងកីឡា ចំនួន៤លើក (៨) ក្រសួងពាណិជ្ជកម្ម ចំនួន២លើក (៩) ក្រសួងព័ត៌មាន ចំនួន១លើក ។

## ៣.២. ការតាមដានការអនុវត្តច្បាប់

ក្រសួងបានចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានានៅតាមបណ្ដារាជធានី ខេត្តចំនួន១៨ សរុបចំនួន២៩លើក ក្នុងនោះការងារកំពុងបន្តចុះតាមដានមានចំនួន ២ករណី ការងារដែលបានបញ្ចប់មានចំនួន ២៧ករណី រួមមាន៖ (១) ច្បាប់ស្ដីពីព្រៃឈើ (២) ច្បាប់ស្ដីពីជលផល (៣) ច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (៤) ច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង (៥) ច្បាប់ស្ដីពីការងារ (៦) អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកំណត់ និងការគ្រប់គ្រងច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា (៧) អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់ (៨) ប្រកាសលេខ២៤៧ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការគ្រប់គ្រងអាជីវកម្មល្បែងកំសាន្ត ស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (៩) ការអនុវត្តកិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី។

ជាលទ្ធផល តាមរយៈការចុះតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ក្នុងឆ្នាំ២០១៨នេះ ជាលទ្ធផលបានរកឃើញនូវចំណុចខ្វះខាត និងកំហុសឆ្គងលើការអនុវត្តច្បាប់ និងបានជំរុញឱ្យកែលម្អរួមមាន៖

- **ច្បាប់ស្ដីពីព្រៃឈើក្នុងខេត្តសៀមរាប ឧត្តរមានជ័យ មណ្ឌលគិរី និងខេត្តព្រះវិហារ**

-រោងសិប្បកម្មផល អនុផលព្រៃឈើ រោងសន្និផល អនុផលព្រៃឈើ និងកន្លែងលក់គ្រឿងសង្ហារិមផល អនុផលព្រៃឈើ មួយចំនួនមិនទាន់មានលិខិតអនុញ្ញាតធ្វើអាជីវកម្មនៅឡើយ។

-ការបង្ក្រាបបទល្មើសព្រៃឈើ របស់ខណ្ឌរដ្ឋបាលព្រៃឈើ ផ្នែករដ្ឋបាលព្រៃឈើ និងសង្កាត់រដ្ឋបាលព្រៃឈើ នៅមិនទាន់អស់លទ្ធភាពនៅឡើយ។

- **ច្បាប់ស្ដីពីជលផលក្នុងខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំង**

-កន្លែងសន្និធិផល ផលិតផលជលផលមួយចំនួន មិនទាន់មានលិខិតអនុញ្ញាតប្រកបអាជីវកម្មនៅឡើយ។

- **ច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ក្នុងខេត្តឧត្តរមានជ័យ ខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ**

-ក្រុមហ៊ុនចំនួន៣កន្លែងនៅខេត្តឧត្តរមានជ័យ មិនទាន់បានបោះបង្គោលកំណត់ព្រំប្រទល់ដែនទៅតាមអាជ្ញាប័ណ្ណបានរួចរាល់នៅឡើយ។

-ក្រសួងរ៉ែ និងថាមពល មានភាពយឺតយ៉ាវក្នុងការផ្ដល់អាជ្ញាប័ណ្ណ បន្តពន្យាសុពលភាព ដល់ម្ចាស់អាជីវកម្មធនធានរ៉ែ។

- **ច្បាប់ស្ដីពីការងារ តាមបណ្ដារោងចក្រ នៅខេត្តតាកែវ**

-រោងចក្រចំនួន៧កន្លែងនៅខេត្តតាកែវ មានកម្មករនិយោជិតមួយចំនួន ពុំទាន់មានសៀវភៅការងារ ប័ណ្ណការងារ និងវិញ្ញាបនប័ត្របញ្ជាក់ការពិនិត្យកាយសម្បទានៅឡើយ។

-មានរោងចក្រចំនួន២កន្លែង នៅខេត្តតាកែវពុំទាន់មានសម្ភារ បរិក្ខារ គ្រែ និងឱសថគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងគិលានដ្ឋានគ្រប់គ្រាន់នៅឡើយ រីឯអាហារដ្ឋានក៏ពុំទាន់ឆ្លើយតប ទៅនឹងចំនួនកម្មករនិយោជិតនៅឡើយ។

-រោងចក្រចំនួន៧កន្លែងនៅខេត្តតាកែវពុំទាន់មានគិលានុបដ្ឋាកយិកាប្រចាំការនៅគិលានដ្ឋានជាប់លាប់នៅឡើយ និងបានជ្រើសរើសយកគ្រូពេទ្យមកធ្វើការនៅក្នុងគិលានដ្ឋានដោយពុំបានបំពេញគ្រប់លក្ខខណ្ឌ។

- **ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង និងប្រកាសលេខ២៤៧ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ នៅខេត្តស្វាយរៀង**

-កាស៊ីណូចំនួន ៨កន្លែងនៅខេត្តស្វាយរៀង ពុំបានបិទបម្រាមហាមជនជាតិខ្មែរចូលលេងល្បែងស៊ីសង នៅក្នុងកាស៊ីណូរបស់ខ្លួននៅឡើយ។

- **អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ នៅខេត្តបាត់ដំបង ព្រៃវែង កំពត ប៉ៃលិន ស្វាយរៀង កណ្តាល ត្បូងឃ្មុំ ក្រចេះ តាកែវ បន្ទាយមានជ័យ កោះកុង ឧត្តរមានជ័យ សៀមរាប រតនគិរី និងរាជធានីភ្នំពេញ**

-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារចំនួន ៧កន្លែង នៅខេត្តស្វាយរៀង កណ្តាល បាត់ដំបង និងខេត្តតាកែវ ពុំមានទីកន្លែងសម្រាប់ត្រួតពិនិត្យទំនិញរួមគ្នានៅឡើយ។

-មន្ត្រីតាមបណ្តាការិយាល័យគយ និងរដ្ឋាករ បានបម្រើការងារហួសអាណត្តិរួមមាន៖

+មន្ត្រីការិយាល័យគយ និងរដ្ឋាករក្អមសំណ ចំនួន៩នាក់ និងមន្ត្រីការិយាល័យគយ និងរដ្ឋាករជ្រៃធំ ចំនួន១៨នាក់ ក្នុងខេត្តកណ្តាល។

+មន្ត្រីការិយាល័យគយ និងរដ្ឋាករដូងចំនួន១០នាក់ មន្ត្រីការិយាល័យគយ និងរដ្ឋាករភ្នំដីចំនួន១៥នាក់ មន្ត្រីការិយាល័យគយ និងរដ្ឋាករអូរអន្លក់ ចំនួន៥នាក់ និងមន្ត្រីការិយាល័យគយ និងរដ្ឋាករ អូររំដួល ចំនួន៩នាក់ក្នុងខេត្តបាត់ដំបង។

+មន្ត្រីការិយាល័យគយ និងរដ្ឋាករបាវិតចំនួន២២នាក់ មន្ត្រីការិយាល័យគយ និងរដ្ឋាករព្រៃវល្លិ៍ ចំនួន២នាក់ និងមន្ត្រីការិយាល័យគយ និងរដ្ឋាករបុសមនចំនួន១នាក់ ក្នុងខេត្តស្វាយរៀង។

+មន្ត្រីការិយាល័យគយ និងរដ្ឋាករស្រែអំបិលចំនួន៩នាក់ក្នុងខេត្តកោះកុង។

+មន្ត្រីសាខាគយ និងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញចំនួន២៨នាក់ និងមន្ត្រីសាខាគយ និងរដ្ឋាករ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញចំនួន៥៥នាក់ ក្នុងរាជធានីភ្នំពេញ។

-មន្ត្រីតាមបណ្តាប៉ុស្តិ៍នគរបាលច្រកទ្វារ បានបម្រើការងារហួសអាណត្តិរួមមាន៖

+មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណចំនួន៣០នាក់ និងមន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ ចំនួន២៥នាក់ ក្នុងខេត្តកណ្តាល។

+មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង ចំនួន៥៩នាក់ ក្នុងខេត្តបាត់ដំបង។

+មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត ចំនួន១៣៤នាក់ មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ចំនួន៣៣នាក់ មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនទ្វេភាគីបុសមន ចំនួន១១នាក់ និងមន្ត្រីប៉ុស្តិ៍ នគរបាលច្រកទ្វារព្រំដែនទ្វេភាគីសំរោង ចំនួន១០នាក់ ក្នុងខេត្តស្វាយរៀង។

+មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន៣៣នាក់ ប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែសមុទ្រស្រែអំបិល ចំនួន៣នាក់ ក្នុងខេត្តកោះកុង។

+មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែអន្តរជាតិភ្នំពេញ ចំនួន១៥នាក់ រាជធានីភ្នំពេញ។

-ក្នុងភូមិសាស្ត្រច្រកទ្វារព្រំដែនក្នុងខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ កំពត និងខេត្តតាកែវ នៅមានច្រករបៀង ព្រមទាំងមានសកម្មភាពរត់ទំនិញគេចពន្ធនៅឡើយ។

- **អនុក្រឹត្យលេខ៨៦អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ នៅខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង**

-សំណង់ផ្ទះល្វែង សណ្ឋាគារ រោងចក្រ និងស្ថានីយ៍ប្រេងឥន្ធនៈមួយចំនួនមិនបានសុំលិខិតអនុញ្ញាតសាងសង់ មិនមានលិខិតអនុញ្ញាតបើកការដ្ឋាន គ្មានលិខិតអនុញ្ញាតបិទការដ្ឋាន គ្មានវិញ្ញាបនបត្របញ្ជាក់ពីភាពត្រឹមត្រូវនៃសំណង់ សាងសង់មុនលិខិតអនុញ្ញាត សាងសង់ខុសពីលិខិតអនុញ្ញាត និងប្រើប្រាស់ក្រុមជាងសំណង់ដែលពុំបានចុះបញ្ជីស្របច្បាប់។

- **កិច្ចសន្យាវិនិយោគ នៅខេត្តតាកែវ**

-ម្ចាស់អាជីវកម្មប្រមូលភាស៊ីចំនួន២កន្លែងនៅខេត្តតាកែវបានប្រមូលថ្លៃភាស៊ី លើសពីតារាងតម្លៃដែលចែងក្នុងសៀវភៅបន្ទុក។

-ម្ចាស់អាជីវកម្មប្រមូលភាស៊ីចំនួន១កន្លែងនៅខេត្តតាកែវ ពុំទាន់បានអនុវត្តការសាងសង់ត្រឹមត្រូវតាមកិច្ចសន្យានៅឡើយ។

-ភ្នាក់ងារប្រមូលភាស៊ីចំនួន២កន្លែងនៅខេត្តតាកែវ ពុំបានស្លៀកពាក់ឯកសណ្ឋាន និងពុំបានប្រើប្រាស់ ប័ណ្ណភាស៊ីដែលចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

## ៣.៣. ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន៩២បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៣៤បណ្តឹង និង មន្ទីររាជធានី-ខេត្តចំនួន៥៨បណ្តឹង)។ ក្នុងនោះរួមមានៈ

-ពាក្យបណ្តឹងកំពុងពិនិត្យ ចំនួន៥បណ្តឹង។

-ពាក្យបណ្តឹងកំពុងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួង ចំនួន២បណ្តឹង។

-ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន១៤បណ្តឹង។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង ចំនួន៨បណ្តឹង និងសមត្ថកិច្ចមន្ទីររាជធានី-ខេត្ត ចំនួន៥៨បណ្តឹង។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការ ចំនួន២បណ្តឹង។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត ចំនួន១បណ្តឹង។

-ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវ ចំនួន៤០បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៣បណ្តឹង និងមន្ទីររាជធានី-ខេត្ត ចំនួន១៧បណ្តឹង)។

-ពាក្យបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវ ចំនួន២បណ្តឹង។

-ពាក្យបណ្តឹងដែលបានបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន១បណ្តឹង។

-ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួង ចំនួន២បណ្តឹង។

-ពាក្យបណ្តឹងបានទទួលការឆ្លើយតប ចំនួន៤បណ្តឹង។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយ ចំនួន២បណ្តឹង។

-ពាក្យបណ្តឹងបានធ្វើលិខិតជំរុញការដោះស្រាយ ចំនួន១បណ្តឹង។

-ពាក្យបណ្តឹងដែលបានចុះជំរុញខ្លឹមសារលិខិតរបស់រាជរដ្ឋាភិបាល ចំនួន១បណ្តឹង។

-ពាក្យបណ្តឹងបានដោះស្រាយចប់ ចំនួន២២បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២០បណ្តឹង)។

-ក្រសួងបានតម្លើងកម្មវិធីទទួលពាក្យបណ្តឹងអនឡាញ ដែលកំពុងបន្តរៀបចំនីតិវិធីដើម្បីអនុវត្តបន្តក្នុងការសម្រួលសេវាទទួលដោះស្រាយ ទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ដើម្បីផ្តល់សេវាកាន់តែទាន់ពេល និងមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋ។

## ៤. វិទ្យាស្ថានជាតិអធិការកិច្ច

វិទ្យាស្ថានជាតិអធិការកិច្ចបានបំពេញការងារដូចខាងក្រោមៈ

-ប្រជុំពិភាក្សា និងណែនាំអំពីការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២៣ របស់វិទ្យាស្ថាន ចំនួន៥លើក។

-ប្រជុំពិភាក្សា និងណែនាំអំពីការធ្វើផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៩-២០២១ របស់វិទ្យាស្ថាន ចំនួន ៨លើក។

-ប្រជុំពិភាក្សា និងណែនាំអំពីការធ្វើផែនការសកម្មភាព ឆ្នាំ២០១៩ របស់វិទ្យាស្ថាន ចំនួន ៨លើក។

-ប្រជុំណែនាំអំពីការធ្វើផែនការថវិការបស់ការិយាល័យចំណុះវិទ្យាស្ថាន ចំនួន ៦លើក។

-ប្រជុំណែនាំអំពីការធ្វើផែនការសកម្មភាពឆ្នាំ២០១៩ របស់ការិយាល័យចំណុះវិទ្យាស្ថាន ចំនួន ៤លើក។

-ប្រជុំពិភាក្សា និងណែនាំអំពីការរៀបចំកញ្ចប់ថវិកា របស់វិទ្យាស្ថានជាតិអធិការកិច្ចឆ្នាំ២០១៩ ចំនួន៣លើក។

-ចូលរួមប្រជុំ និងទទួលការណែនាំពីការការពារកញ្ចប់ថវិការបស់វិទ្យាស្ថានជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃអង្គារ ទី៣១ ខែកក្កដា ឆ្នាំ២០១៨។

-ប្រជុំពិភាក្សា និងណែនាំអំពីការរៀបចំខ្លឹមសារ ដើម្បីត្រៀមការពារកញ្ចប់ថវិកាឆ្នាំ ២០១៩ របស់វិទ្យាស្ថានជាតិអធិការកិច្ច និងបញ្ហាផ្សេងៗ ចំនួន២លើក។

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១លើកទិសដៅការងារឆមាសទី២ឆ្នាំ២០១៨ របស់វិទ្យាស្ថានជាតិអធិការកិច្ច នៅថ្ងៃចន្ទ ទី១០ ខែកញ្ញា ឆ្នាំ២០១៨។

-ប្រជុំផ្សព្វផ្សាយពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ និងមន្ត្រីថ្មី នៃវិទ្យាស្ថានជាតិអធិការកិច្ចនៅថ្ងៃចន្ទ ទី១៧ ខែកញ្ញា ឆ្នាំ២០១៨។

-ប្រជុំផ្សព្វផ្សាយពីបេបរបាយការណ៍ និងទម្រង់លិខិតរដ្ឋបាល របស់វិទ្យាស្ថានជាតិអធិការកិច្ច នៅថ្ងៃពុធ ទី៣១ ខែតុលា ឆ្នាំ២០១៨។

-រៀបចំប្រកាសស្តីពីការប្រើប្រាស់ត្រា និងនិមិត្តសញ្ញារបស់វិទ្យាស្ថានជាតិអធិការកិច្ច បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ របស់វិទ្យាស្ថានជាតិអធិការកិច្ច ហើយថ្នាក់ដឹកនាំក្រសួងបានចុះហត្ថលេខាឯកភាពនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២៣ របស់វិទ្យាស្ថានជាតិអធិការកិច្ច ហើយថ្នាក់ ដឹកនាំក្រសួងបានចុះហត្ថលេខាឯកភាពនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។

-រៀបចំផែនការសកម្មភាពឆ្នាំ២០១៩របស់វិទ្យាស្ថានជាតិអធិការកិច្ច ហើយថ្នាក់ដឹកនាំក្រសួងបានចុះហត្ថលេខាឯកភាពនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។

-រៀបចំគម្រោងចំណាយថវិកាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-រៀបចំកម្មវិធីបណ្តុះបណ្តាលឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-ចេញសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចសម្រាប់ថ្នាក់ដឹកនាំវិទ្យាស្ថានជាតិអធិការកិច្ច។

-ចេញសេចក្តីសម្រេចចាត់តាំងមន្ត្រីថ្មីចំនួន ០៦រូប ឲ្យទៅបម្រើការងារ តាមការិយាល័យ នីមួយៗ ចំណុះ វិទ្យាស្ថានជាតិអធិការកិច្ច។

-ទំនាក់ទំនង និងបានបញ្ជូនមន្ត្រី២រូបរបស់វិទ្យាស្ថានទៅចូលរួមវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងបណ្ណាល័យនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។

-ទំនាក់ទំនង និងបានទទួលសៀវភៅចម្រុះមុខវិជ្ជាចំនួន ៩៦ក្បាល ពីអង្គការខេប (KAPE)។

-បណ្តុះបណ្តាលវគ្គសិក្សាជំនាញអធិការកិច្ចបឋមស្តីពី "មូលដ្ឋានគ្រឹះ នៃការងារអធិការកិច្ច" ចំនួន ១ វគ្គ រយៈពេល ៥ ថ្ងៃចាប់ពី ថ្ងៃទី ២៦ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ នៅវិទ្យាស្ថានជាតិអធិការកិច្ច។ ពិធីបើកវគ្គ ត្រូវបានឯកឧត្តម រដ្ឋលេខាធិការ **ចាប សុថារិទ្ធ** ធ្វើជាអធិបតី និងពិធីបិទវគ្គ និងពិធីចែកវិញ្ញាបនបត្រត្រូវបានឯកឧត្តម រដ្ឋលេខាធិការ **ថាច់ ឃន** ធ្វើជាអធិបតី។

## ៥. សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងបានបំពេញការងារដូចខាងក្រោមៈ

-ចុះតាមដានអនុសាសន៍របស់សវនករក្នុងការិយបរិច្ឆេទ២០១៦ នៅតាមបណ្តាសវនដ្ឋានបានចំនួន១២មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពត ក្រចេះ កំពង់ចាម កែប កំពង់ឆ្នាំង កំពង់ធំ តាកែវ ត្បូងឃ្មុំ ប៉ៃលិន បាត់ដំបង សៀមរាប និងខេត្តពោធិ៍សាត់។

-ចុះធ្វើសវនកម្មផ្ទៃក្នុង ក្នុងការិយបរិច្ឆេទ២០១៧ នៅតាមទីសវនដ្ឋាន បានចំនួន១៦មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តតាកែវ ប៉ៃលិន បាត់ដំបង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រះសីហនុ កំពង់ឆ្នាំង កំពង់ចាម កោះកុង ព្រះវិហារ និងខេត្តស្ទឹងត្រែង។

-ធ្វើរបាយការណ៍ស្តីពីការចុះធ្វើសវនកម្ម នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តតាកែវ ប៉ៃលិន បាត់ដំបង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រះសីហនុ កំពង់ឆ្នាំង កំពង់ចាម កោះកុង ព្រះវិហារ និងខេត្តស្ទឹងត្រែង។

-ផ្តល់អនុសាសន៍ ចែករំលែកបទពិសោធន៍ និងធ្វើការណែនាំដល់មន្ទីរទាំងអស់ ឱ្យអនុវត្តការងារបច្ចេកទេស ការដឹកនាំគ្រប់គ្រងមន្ត្រីរាជការ ការងារហិរញ្ញវត្ថុ ជាពិសេសការចំណាយផ្សេងៗ នៅក្នុងសាម៉ីមន្ទីរឱ្យបានត្រឹមត្រូវ មានលក្ខណៈសមស្រប អនុលោមទៅតាមច្បាប់ សារាចរណែនាំផ្សេងៗ និងនីតិវិធីហិរញ្ញវត្ថុតាមបណ្តាឆ្នាំនីមួយៗ។

# ៦. ការងារផ្សេងទៀត

## ៦.១ យេនឌ័រ

ក្រសួងបានបង្កើតក្រុមការងារយេនឌ័រ និងបានសម្រេចការងារដូចខាងក្រោម៖

-ក្នុងឱកាសទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ តាមការអញ្ជើញរបស់ក្រសួងកិច្ចការនារី សមាជិកក្រុមការងារបច្ចេកទេសយេនឌ័រ ចំនួន៣រូបបានចូលរួមក្រាបបង្គំគាល់ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម **មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះប្រធានកិត្តិយស នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចូលរួមសម្តែងការគួរសមជាមួយសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងសម្តែងការគួរសមជាមួយសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

-ក្រុមការងារបច្ចេកទេសយេនឌ័រ និងសមាជិកចំនួន៥៤រូប បានចូលរួមអបអរសាទរខួបលើកទី ១០៧ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទ និងពិព័រណ៍កោះពេជ្រ។

-ចូលរួមពិធីមីទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាជ័យជម្នះ៧មករា (៧/១/១៩៧៩-៧/១/២០១៨) ក្រោមអធិបតីភាព សម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពពិព័រណ៍កោះពេជ្រ។

-រៀបចំកម្មវិធីខួបលើកទី១០៧ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ ក្រោមប្រធានបទ «ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព» ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅទីស្តីការក្រសួង។

-ចូលរួមចុះសួរសុខទុក្ខកងកម្លាំងនគរបាលជាតិការពារព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តកោះកុង ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ចូលរួមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅអនុវត្តសម្រាប់ឆ្នាំ២០១៨ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី នៅសណ្ឋាគារសុខាភ្នំពេញ។

-ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួង ស្ថាប័ន រៀបចំដោយក្រសួងកិច្ចការនារី និងដៃគូរអភិវឌ្ឍន៍ ដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម បទពិសោធន៍ និងទិសដៅផែនការបន្តសម្រាប់អនុវត្តឆ្នាំ២០១៩ ស្តីពីការបញ្ជ្រាបយេនឌ័រ នៅខេត្តសៀមរាប។

-ចូលរួមពិធីមីទ្ទីញមហាជន នៅសារមន្ទីរជាតិ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីអបអរសាទរ «ល្ខោនខោល» ដែលជាស្នាដៃសិល្បៈបុរាណដ៏វិសេសវិសាលអស្ចារ្យរបស់កម្ពុជាត្រូវបានអង្គការយូនីស្កូសម្រេចដាក់ក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោកអរូបី នៃ មនុស្សជាតិ ក្នុងឱកាសកិច្ចប្រជុំលើកទី១៣ នៅទីក្រុងព័រល្វី (Port Louis) នៃសាធារណរដ្ឋម៉ូរីស (Mauritius) នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ និងការបង្ហាញក្រម៉ាកម្ពុជា ដែលវែងជាងគេបង្អស់ក្នុងពិភពលោក ។

-ចូលរួមពិធីមីទ្ទីញមហាជនអបអរសាទរខួបលើកទី៤០ (២ធ្នូ ១៩៧៨-២ធ្នូ ២០១៨) ទិវាកំណើតរណសិរ្ស សាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅវិមានអនុស្សាវរីយ៍២ធ្នូ ស្ថិតនៅភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

-ចូលរួមយុទ្ធនាការ «៤០គីឡូម៉ែត្រទៅកាន់ប្រវត្តិសាស្ត្រ» ដែលធ្វើដំណើរពីភ្នំពេញទៅខេត្តក្រចេះជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីអបអរសាទរ និងជាការរំលឹកដល់ខួបអនុស្សាវរីយ៍លើកទី៤០ ទិវាកំណើតរណសិរ្ស សាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា។

-ចូលរួមកម្មវិធីជ័យជម្នះ៧មករា ក្រោមនយោបាយ «ឈ្នះឈ្នះ» របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០១៨ នៅវិមានឈ្នះឈ្នះ។

-បានចុះសួរសុខទុក្ខ និងឧបត្ថម្ភដល់មន្ត្រីរាជការ ដែលមានជម្ងឺ ក្រលំបាក លំហែមាតុភាព

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពឥស្សរជនដឹកនាំបក្ស រដ្ឋាភិបាល និងឥស្សរជនកំពូលបរទេសជាមិត្តដែលទទួលមរណភាព។

-ក្រៅពីការងារស្នូលក្រុមការងារបច្ចេកទេសយេនឌ័រ និងថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងស្ត្រី និងបុរសបានអនុវត្តការងារប្រចាំថ្ងៃ នៅតាមអគ្គនាយកដ្ឋាននីមួយៗដូចជា៖ ការងាររដ្ឋបាលកិច្ចការទូទៅ ការងារហិរញ្ញវត្ថុ ការងារអធិការកិច្ច ការងារអប់រំផ្សព្វផ្សាយច្បាប់ ការងារនីតិកម្ម ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការងារសហប្រតិបត្តិការ អន្តរជាតិ ការងារសវនកម្មផ្ទៃក្នុង ការងារថ្នាក់ជាតិ និងការងារផ្សេងៗទៀត ដែលក្រសួង និងរាជរដ្ឋាភិបាល បានប្រគល់ជូនកំពុងដំណើរការប្រកបដោយប្រសិទ្ធភាព។

ជាមួយលទ្ធផល និងស្នាដៃដែលសម្រេចបានខាងលើ ថ្នាក់ដឹកនាំ មន្ត្រីរាជការជាស្ត្រីចំនួន១២៥រូបត្រូវទទួលបានការលើកទឹកចិត្តក្នុងការតម្លើងឋានៈ និងតួនាទី ក្នុងនោះ ចំនួន២៨រូបបានទទួលបានគ្រឿងឥស្សរិយយសគ្រប់ប្រភេទពីរាជរដ្ឋាភិបាល និងចំនួន៣៣រូបត្រូវបានបញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញ និងសមត្ថភាពថែមទៀតទាំងក្នុង និងក្រៅប្រទេស។

### ៦.២. ការចងសម្ព័ន្ធមេត្រីភាព

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដោយសហការជាមួយក្រុមហ៊ុនម៉ុង ឬទ្ធីគ្រុប ក្រុមហ៊ុនគូហ៊ូឡុង និងបណ្ដាសម្បុរសជន រួមទាំងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចូលរួមបរិច្ចាកធនធានមានទាំងសម្ភារៈ និងថវិកា ដើម្បីរួមចំណែក ជួយគាំទ្រ និងលើកទឹកចិត្តដល់កងកម្លាំងប្រដាប់អាវុធយ៉ាងអង់អាចក្លាហានរបស់យើង ដែលកំពុងឈរជើងប្រចាំការ បំពេញភារកិច្ចដ៏ឧត្តមការពារបូរណភាពទឹកដី ក្នុងភូមិសាស្ត្រខេត្តកោះកុងនេះកាន់តែមានកម្លាំងចិត្ត និងភាពកក់ក្ដៅថែមទៀត។

កាលពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៨ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងបានចុះជួបសំណេះសំណាល ជាមួយកងកម្លាំងប្រដាប់អាវុធអង្គភាពនគរបាលជាតិ វរសេនាតូចលេខ៨២៧ និងវរសេនាតូចលេខ២៦៩ ដែលឈរជើងក្នុងភូមិសាស្ត្រខេត្តកោះកុង ដោយបាននាំយកថវិកា និងអំណោយជាគ្រឿងឧបភោគបរិភោគចែកជូនដល់អង្គភាពទាំងពីរ សរុបជាថវិកាចំនួន១១៤ ៧៩៧ ០០០រៀល (មួយរយដប់បួនលានប្រាំពីររយកៅសិបប្រាំពីរពាន់រៀល)។ ក្នុងនោះបានឧបត្ថម្ភដល់វរសេនាតូចលេខ៨២៧ នគរបាលការពារព្រំដែនគោកចំនួន១២៣នាក់ ថវិកាចំនួន ៦ ០០០ ០០០ រៀល (ប្រាំមួយលានរៀល) ស័ង្កសីចំនួន៣០០សន្លឹក និងបានជួសជុលរបងអស់ថវិកា ៧.០៥៤ ដុល្លារអាមេរិក (ប្រាំពីរពាន់ហាសិបបួនដុល្លារអាមេរិក) វរសេនាតូចលេខ២៦៩ នគរបាលការពារព្រំដែនទឹកចំនួន១១០នាក់ ថវិកាចំនួន ៥ ០០០០០០រៀល (ប្រាំលានរៀលគត់) ទីបញ្ជាការប្រចាំទិសភូមិភាគ៣ចំនួន១៦នាក់ ថវិកាចំនួន២ ០០០០០០រៀល (ពីរលានរៀលគត់) និងពលនគរបាលម្នាក់ៗទទួលបានអង្ករ៥០គីឡូក្រាម មីយើង ១កេស ត្រីខកំប៉ុង១យួរ សៀង១យួរ ផៃប៉ូវផ្អែម២គីឡូក្រាម ទឹកសុទ្ធ១កេស ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ នំប៉ុងបាក់យ៉ុង១ដើម និងឃីត១កញ្ចប់(ថ្នាំពេទ្យ ក្រមា ប្រេងកូឡា សាប៊ូ ថ្នាំដុសធ្មេញ)។

### ៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន

ក្រសួងបានបង្កើតក្រុមការងារគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន។ ក្រុមការងារបានប្រជុំជាច្រើនលើក ដើម្បីធ្វើផែនការ និងរៀបចំកសាងគេហទំព័រថ្មីរបស់ក្រសួង ដោយធ្វើបច្ចុប្បន្នភាពព័ត៌មាន បន្ថែមសុវត្ថិភាពទប់ទល់នឹងការជ្រៀតចូល (Hacking) និងតម្លើងកម្មវិធីថ្មី (Application) សម្រាប់ដាក់ពាក្យបណ្ដឹងអនឡាញ។ ក្រសួងបានកែសម្រួលគេហទំព័រផ្លូវការរបស់ខ្លួន ដោយបន្ថែមប៊ូតុង ១) "ការដាក់ពាក្យបណ្ដឹង" ២) បណ្ណាល័យអេឡិចត្រូនិក (E-Library)។

ក្រសួងក៏បានបង្កើតក្រុមក្នុងកម្មវិធី តេឡេក្រាម ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នាឱ្យបានឆាប់រហ័ស។

### ៦.៤. អ្នកនាំពាក្យក្រសួង

ក្រសួងបានបង្កើតអ្នកនាំពាក្យ ដើម្បីបំពេញការងារប្រតិកម្មរហ័ស ឆ្លើយតបទៅនឹងព្រឹត្តិការណ៍សំខាន់ៗ របស់ក្រសួង និងបញ្ជូនព័ត៌មានទាន់ហេតុការណ៍នានា ដាក់ក្នុងបណ្ដាញផ្សព្វផ្សាយ និងគេហទំព័រក្រសួង។

## គ. ការប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

-ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅមិនទាន់បានអនុម័តនៅឡើយ។

-ការអនុវត្តការងារតាមតួនាទីភារកិច្ចតាមអង្គភាពនីមួយៗមិនទាន់បានល្អប្រសើរ តាមឋានានុក្រម និងនីតិវិធីនៅឡើយ។

-នៅមានការលំបាក ក្នុងការចុះធ្វើបេសកកម្ម ដោយកង្វះថវិកាបុរេប្រទានគ្រប់គ្រាន់ និងខ្វះមធ្យោបាយធ្វើដំណើរ និងសម្ភារបច្ចេកវិទ្យាសម្រាប់ចុះបេសកកម្ម។

-សមត្ថភាពជំនាញរបស់មន្ត្រីរាជការអធិការកិច្ចមួយចំនួនតូចនៅមានកម្រិតនៅឡើយ។

-ពុំទាន់មានដៃគូរអភិវឌ្ឍជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

-កិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង-ស្ថាប័ននៅមានកម្រិត។

-ចំនួនមន្ត្រីរាជការតិចតួចមិនទាន់ឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង។

-កិច្ចសហការរបស់អង្គភាពរងអធិការកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួននៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យឆ្លងប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច ចុះហត្ថលេខាយល់ព្រមលើលទ្ធផលអធិការកិច្ច។

-ការចុះផ្សព្វផ្សាយច្បាប់នៅមានការខ្វះខាតមធ្យោបាយធ្វើដំណើររួម (រថយន្តរដ្ឋ) ។

-ការទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹងនៅមានការខ្វះខាត ដោយកង្វះថវិកា និងមធ្យោបាយផ្សេងៗ។

-ការបណ្តុះបណ្តាលតាមរយៈវិទ្យាស្ថានជាតិ អធិការកិច្ចមានការលំបាកដោយមន្ទីររាជធានី ខេត្តមានការខ្វះខាតថវិកា ដើម្បីបញ្ជូនសិក្ខាកាមមករៀន។

## ឃ. ទិសដៅការងារបន្ត

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទីភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាពដូចខាងក្រោម៖

# ១.រដ្ឋបាលកិច្ចការទូទៅ

## ១.១. រដ្ឋបាល

-បន្តអនុវត្តចរន្តការងាររដ្ឋបាលរួមមានលិខិតចេញ និងចូល និងការជូនដំណឹងផ្សេងៗផ្ទៃក្នុងឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

## ១.២. បុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ និងមន្ត្រីបាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

## ១.៣. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

-បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ តាមជំពូក តាមសកម្មភាព ចង្កោមសកម្មភាព អនុកម្មវិធី នៃកម្មវិធី ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់ការងារបៀវត្សដំណើរការរដ្ឋបាលទូទៅ និងបេសកកម្មក្នុងប្រទេស ។ល។

-ចុះកិច្ចបញ្ជិកាគណនេយ្យជាប្រចាំ និងគ្រប់គ្រងព័ត៌មានវិទ្យា ជាពិសេសក្នុងសកម្មភាពហិរញ្ញវត្ថុ គ្រប់គ្រងចំណាយឱ្យបានសមស្រប។

-ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកាឱ្យសមស្របតាមគម្រោងថវិការដ្ឋ ប្រមូលផ្តុំតម្រូវការ និងសម្របសម្រួលរាល់ការចំណាយ។

-ត្រួតពិនិត្យបច្ចេកទេសនូវការអនុវត្តលទ្ធកម្មសាធារណៈ។

-គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវសន្និធិ។

-ទទួលបែងចែក និងជួសជុល សម្ភារ បរិក្ខារ ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួង។

-គ្រប់គ្រង និងបែងចែកប្រេងឥន្ធនៈ និងប្រាក់បេសកកម្ម។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ។

## ១.៤. ផែនការ និងស្ថិតិ

-បន្តរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២០-២០២២របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើជូនក្រសួងផែនការ។

-បន្តចុះណែនាំលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី -ខេត្តទាំង២៥ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តរៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំ២០១៩ ទាំងរដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្តទាំង២៥ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច (ហើយចូលរួមកិច្ចប្រជុំចរចាកម្រិតបច្ចេកទេស និងចរចា កម្រិតថ្នាក់ដឹកនាំក្រសួង និងក្រសួង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

-បន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ (ផយអជ) ផ្ញើជូនក្រសួងផែនការ។

-បន្តរៀបចំសេចក្តីព្រាងផែនការសកម្មភាព ស្តីពីការអប់រំផ្សព្វផ្សាយច្បាប់ ឆ្នាំ២០២០-២០២២ សម្រាប់ជាធាតុចូលរួមចំណែកអនុវត្ត នៃគោលនយោបាយជាតិប្រជាជនឆ្នាំ ២០១៦-២០៣០។

-បន្តរៀបចំរបាយការណ៍ស្តីពីស្ថិតិផ្លូវការមានការចាត់តាំងរួមមាន៖ ការអនុម័តច្បាប់ ការងារអប់រំផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ផ្ញើជូនក្រសួងផែនការ ទាន់ពេលវេលា។

-បន្តរៀបចំសៀវភៅស្ថិតិទូទៅមន្ត្រីរាជការ និងថ្នាក់ដឹកនាំរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី -ខេត្តទាំង២៥នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តអនុវត្តការងារតាមតួនាទីភារកិច្ចរបស់នាយកដ្ឋានផែនការ និងស្ថិតិ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ១.៥. សហប្រតិបត្តិការអន្តរជាតិ

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI)និងវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

-បង្កើនទំនាក់ទំនងជាមួយស្ថានទូត នៃព្រះរាជាណាចក្រថៃប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញទំនាក់ទំនងកិច្ចសហប្រតិបត្តិការ រវាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចជាមួយការិយាល័យ OMBUDSMAN នៃព្រះរាជាណាចក្រថៃ លើវិស័យអធិការកិច្ច។

## ២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១. នីតិកម្ម

-ចូលរួមរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

-ចុះស្ទង់មតិប្រជាពលរដ្ឋ នៅតាមបណ្តាខេត្តគោលដៅដែលបានគ្រោងទុក។

-សិក្សាស្រាវជ្រាវ និងប្រមូលឯកសារច្បាប់។

-រៀបចំសិក្ខាសាលាបំពាក់បំប៉នជំនាញស្ទង់មតិ និងបញ្ចូលទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ។

-រៀបចំបញ្ចូលទិន្នន័យជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិក្នុងបណ្ណាល័យអេឡិចត្រូនិច។

### ២.២. ការអប់រំផ្សព្វផ្សាយច្បាប់

-ទំនាក់ទំនងជាមួយបណ្តារាជធានី-ខេត្ត ដើម្បីចុះផ្សព្វផ្សាយច្បាប់។

-សិក្សាស្រាវជ្រាវឯកសារ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់។

-ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃមុន និងក្រោយការផ្សព្វផ្សាយច្បាប់។

-ចុះផ្សព្វផ្សាយច្បាប់នៅតាមបណ្តាខេត្តគោលដៅ។

### ២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួង និងតាមក្រសួង ស្ថាប័ន។

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គវិសាមញ្ញ នៅមន្ទីររដ្ឋសភា-ព្រឹទ្ធសភា។

-ចុះអមដំណើរជាមួយគណៈកម្មការនានានៃរដ្ឋសភា និងក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ។

-ចុះធ្វើវេទិកាសាធារណៈ។

## ៣. អធិការកិច្ច

### ៣.១. អធិការកិច្ច

-ត្រៀមឆ្លងរបាយការណ៍ដែលបានបញ្ចប់ការចុះធ្វើអធិការកិច្ច លើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៧ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួង និងតាមបណ្តាមន្ទីរ-អង្គភាព ដែលនៅសេសសល់ក្នុងឆ្នាំ២០១៨។

-ត្រៀមខ្លឹមសារឯកសារ "នីតិវិធីអធិការកិច្ច" ដើម្បីដាក់ឆ្លងថ្នាក់ដឹកនាំក្រសួង។

-បន្តចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៧ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួង និងបណ្តាមន្ទីរ-អង្គភាព មួយចំនួនក្នុងរាជធានីភ្នំពេញមិនទាន់ធ្វើចប់ក្នុងឆ្នាំ២០១៨។

-រៀបចំធ្វើសេចក្តីជូនដំណឹងទៅបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធដែលនៅសេសសល់ពីឆ្នាំ២០១៨។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០១៩។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣-២-ការតាមដានការអនុវត្តច្បាប់

-ត្រៀមឆ្លងរបាយការណ៍លទ្ធផល នៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលនៅសេសសល់ក្នុងឆ្នាំ២០១៨។

-ត្រៀមខ្លឹមសារឯកសារ "នីតិវិធីនាំការតាមដានអនុវត្តច្បាប់" ដើម្បីដាក់ឆ្លងថ្នាក់ដឹកនាំក្រសួង។

-ត្រៀមរៀបចំធ្វើសេចក្តីជូនដំណឹងស្តីពីការកែលម្អលើចំណុចខ្វះខាត ទៅតាមបណ្តាក្រសួង-ស្ថាប័ន។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០១៩។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣-៣-ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

-បន្តទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ។

-ត្រៀមខ្លឹមសារឯកសារ "នីតិវិធីនៃការដាក់ពាក្យបណ្តឹង និងការដោះស្រាយពាក្យបណ្តឹង" ដើម្បីដាក់ឆ្លងថ្នាក់ដឹកនាំក្រសួង។

-រង់ចាំការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួង ដើម្បីជំរុញការអនុវត្តលទ្ធផលពាក្យបណ្តឹង ដែលបានបញ្ជូនទៅគ្រប់ស្ថាប័ន និងបណ្តារាជធានី-ខេត្តកន្លងមក។

-បន្តនឹងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០១៩។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

## ៤. វិទ្យាស្ថានជាតិអធិការកិច្ច

វិទ្យាស្ថានជាតិអធិការកិច្ចកំណត់យក ទិសដៅការងារជាយុទ្ធសាស្ត្រដូចខាងក្រោមៈ

-កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធ រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន រៀបចំវិធីសាស្ត្រ នៃការជ្រើសរើសសិក្ខាកាម គ្រូឧទ្ទេស និងសាស្ត្រាចារ្យ រៀបចំក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនអធិការកិច្ចរៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

-អភិវឌ្ឍស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រងស្នើសុំទីតាំងវិទ្យាស្ថាន អគារសិក្សា ការិយាល័យ និងសម្ភារបរិក្ខារ។

-ស្នើសុំបណ្ណាល័យ រោងពុម្ព និងសម្ភារបរិក្ខារ មធ្យោបាយធ្វើដំណើរសម្រាប់វិទ្យាស្ថាន។

-រៀបចំបង្កើតប្រព័ន្ធព័ត៌មានវិទ្យា។

-រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថានមួយច្បាស់លាស់មួយដែលមានការបែងចែកភារកិច្ច ទៅឱ្យគ្រប់ថ្នាក់ដឹកនាំ រួមមានប្រធាន អនុប្រធាន វិទ្យាស្ថាន និងការិយាល័យចំណុះ។

-បង្កើតក្រុមប្រឹក្សាភិបាលសម្រាប់វិទ្យាស្ថាន។

-កសាងសមត្ថភាព និងពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំវិទ្យាស្ថាន ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរបស់វិទ្យាស្ថានអំពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។

-ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរបស់វិទ្យាស្ថានអំពីការស្រាវជ្រាវ និងព័ត៌មានវិទ្យា។

-ពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងហិរញ្ញវត្ថុ គ្រប់គ្រងការងារចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារបរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន គ្រប់គ្រងការងារបុគ្គលិក ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ គ្រប់គ្រងការងារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

-ពង្រឹងការងារគ្រប់គ្រងផែនការ និងស្រាវជ្រាវ។

-ធ្វើបច្ចុប្បន្នភាពផែនការនានារបស់វិទ្យាស្ថាន។

-រៀបចំ ចងក្រងសៀវភៅ ឯកសារ និងអត្ថបទនានាទាក់ទងនឹងជំនាញអធិការកិច្ច។

-បន្តផ្តល់ការបណ្តុះបណ្តាលជំនាញអធិការកិច្ចរយៈពេលខ្លី លើអធិការកិច្ចកម្រិតបឋម ដល់មន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

-ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសនានា ជាមួយអង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងជាមួយគ្រឹះស្ថានសិក្សា ផ្សេងៗដើម្បីអភិវឌ្ឍសមត្ថភាពវិទ្យាស្ថាន។

# ៥. សវនកម្មផ្ទៃក្នុង

បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន-ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

# ៦. ការងារផ្សេងទៀត

## ៦.១. យេនឌ័រ

-រៀបចំសៀវភៅផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០១៨-២០២៣។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកាយេនឌ័រក្រសួងឆ្នាំ២០១៩ ស្របតាមផែនការយុទ្ធសាស្ត្រថវិកា របស់ក្រសួង និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

-រៀបចំអបអរសាទរខួបលើកទី១០៩ទិវាអន្តជាតិនារីផមីនាជាបន្តបន្ទាប់។

-ផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ អនុសាសន៍១២ចំនុចរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអនុសាសន៍៦ចំនុច របស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកិត្តិយសនៃគណៈកម្មការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ នៅក្រសួង និងនៅតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ជួបសំណេះសំណាលជាមួយមន្ត្រីរាជការដើម្បី «ស្វែងយល់ពីតម្រូវការ និងការប្រឈមរបស់មន្ត្រីរាជការស្ត្រីក្នុងក្រសួង»។

-ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។

-ផ្តល់វគ្គបំពាក់បំប៉នសមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំ។

-ពិនិត្យតាមដានការអនុវត្តការងារបញ្ជ្រាបយេនឌ័រ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្ត។

-ស្វែងរកដៃគូរជួយឧបត្ថម្ភកម្មវិធីនានាដែលទាក់ទងនឹងយេនឌ័រ។

### ៦.២. ការចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាព ជាមួយកងវរសេនាតូចនគរបាលការពារព្រំដែនទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើនជីវភាពរស់នៅរបស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។ ក្រសួងនឹងរួមសហការជាមួយ ក្រុមហ៊ុន ម៉ុង ឬទ្ធី គ្រុប និងក្រុមហ៊ុន គូ ហ៊ូឡុង ដើម្បីបន្តចុះជួបសំណេះសំណាល ជាមួយអង្គភាពនគរបាលទាំងពីរ ជារៀងរាល់ឆ្នាំ។

### ៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន

ដាក់ឱ្យដំណើការគេហទំព័រថ្មីរបស់ក្រសួង ដោយសារគេហទំព័រចាស់របស់ក្រសួង ត្រូវបានគាំងមិនដំណើការអស់ពេលជាច្រើនខែ។ ត្រូវចាត់តាំងក្រុមការងារជំនាញស្ម័គ្រចិត្តជួយអភិវឌ្ឍ គេហទំព័រក្រសួងធ្វើបច្ចុប្បន្នភាព ជាប្រចាំ និងមានសោភ័ណភាព ខ្លឹមសារ គុណភាព និងសុវត្ថិភាពល្អជាងមុន។

តម្លើង និងបញ្ចូលកម្មវិធី (Application) ថ្មី ដែលក្រុមការងារបានរៀបចំរួចជាស្រេចនូវកម្មវិធីថ្មីភ្ជាប់ក្នុងគេហទំព័រថ្មីរបស់ក្រសួង សម្រាប់ដាក់ និងទទួលពាក្យបណ្តឹងអនឡាញ និងអ៊ីបណ្ណាល័យ ដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងបានតាមរយៈទូរស័ព្ទដៃ ចូលក្នុងកម្មវិធីមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ផ្សេងៗបានយ៉ាងងាយ។

ក្រុមការងារគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានត្រូវជ្រើសរើសយកបុគ្គលិកដែលមានជំនាញផ្នែកបច្ចេកវិទ្យាព័ត៌មាន និងត្រូវកែសម្រួលសេចក្តីសម្រេចលេខ ០១៣/១៨ ដើម្បីកែសម្រួលសមាសភាព និងភារកិច្ច និងដាក់បន្ថែម មន្ត្រីជំនាញខ្លះ (មន្ត្រីជាប់កិច្ចសន្យា) ដើម្បីតាមដាន និងធ្វើបច្ចុប្បន្នភាពគេហទំព័រ និងកម្មវិធីនានា ឱ្យកាន់តែមានប្រសិទ្ធភាព។

### ៦.៤. អ្នកនាំពាក្យក្រសួង

ពង្រឹងការងារអ្នកនាំពាក្យក្រសួងថែមទៀត តាមរយៈបណ្តុះបណ្តាល ចូលរួមកិច្ចប្រជុំនានា ដើម្បីក្តាប់ឱ្យបាននូវការងារក្រសួង និងការងារពាក់ព័ន្ធផ្សេងទៀត និងបំពាក់មធ្យោបាយ បច្ចេកទេសផ្សេងៗ ដើម្បីចេញសេចក្តីប្រកាសព័ត៌មាន ផ្សព្វផ្សាយ និងបកស្រាយព័ត៌មានរបស់ក្រសួង និងរាជរដ្ឋាភិបាលឱ្យទាន់ហេតុការណ៍។

# ខ. សេចក្តីសន្និដ្ឋាន

ក្រសួងបានបំពេញភារកិច្ច ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព និងជោគជ័យ ទោះជាការងារខ្លះមានការលំបាក ស្មុគស្មាញមានភាពរសើប និងភាពចម្រូងចម្រាស់ក្តី។ សមិទ្ធផលការងារ ដូចបានរៀបរាប់ខាងដើមបានមកដោយសារមានការដឹកនាំ ប្រកបដោយបញ្ញាញាណដ៏ភ្លឺស្វាង

និងវាងវៃរបស់លោកជំទាវ ឧបនាយករដ្ឋមន្ត្រី និងដោយសារថ្នាក់ដឹកនាំ មន្ត្រីមានសមត្ថភាពពេញលេញ និងជំនាញច្បាស់លាស់ និងការយល់ដឹងផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។

ដោយសារនៅមានទស្សនៈខុសឆ្គងអំពីតួនាទីរបស់ក្រសួង បុគ្គល និងស្ថាប័នមួយចំនួនបានសម្តែងភាពមិនពេញចិត្ត មិនសប្បាយចិត្ត និងមិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារក្រសួង ជាពិសេសក្រុមអធិការកិច្ច ដែលត្រូវចុះទៅបំពេញបេសកកម្ម នៅតាមស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រោះគេខ្លាចយើងរកឃើញកំហុសឆ្គងនានា ដែលនាំមកនូវបញ្ហាផ្សេងៗដល់ពួកគាត់។

ទន្ទឹមនឹងនេះ ក្រសួងនៅមានការប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួនមិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ និងមានក្រសួង។ ម៉្យាងទៀត នៅមានភាពមិនច្បាស់លាស់ក្នុងតួនាទីរបស់ក្រសួង ដោយសារមានស្ថាប័នរដ្ឋមួយចំនួនមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នា ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ និងអគ្គាធិការដ្ឋាន នៃក្រសួង ស្ថាប័នមួយចំនួនទៀត។ ម្យ៉ាងទៀត ការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះធ្វើបេសកកម្មអធិការកិច្ច ក៏នៅមានការខ្វះខាត និងជួបបញ្ហាខ្លះ។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មទៅតាមច្បាប់អនុញ្ញាត និងតាមបញ្ជារបស់រាជរដ្ឋាភិបាល ហើយយើងបានឃើញច្បាស់ថាការងាររបស់យើង ពិតជាមានតម្លៃយ៉ាងថ្លៃថ្លា ដោយបានជួយធានាការពង្រឹងប្រសិទ្ធភាពការងារ របស់ស្ថាប័ន-អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធសេរីភាពជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋឱ្យបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេងថវិកា និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅ ជាដើម។

ក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា និងអធិការកិច្ចបានតម្រង់ទិស និងណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ដូច្នេះការងារអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបំរើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជាទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោម ការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានធ្វើឱ្យមន្ត្រីរាជការ ក្រសួងកាន់តែមានមោទនភាព ហើយតួនាទីភារកិច្ច ការទទួលខុសត្រូវរបស់ក្រសួងកាន់តែមានសារៈសំខាន់ និងរួមចំណែកដល់ការជម្រុញអភិបាលកិច្ចល្អ។ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវខ្ពស់។

កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការគាំទ្រ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់លោកជំទាវ កិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែណែនាំ តម្រង់ទិស និងកែតម្រូវ និងនៅជិតស្និទ្ធជាមួយ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងជាប់ជាប្រចាំ។ លើសពីនេះ ក្រសួងដំណើរការទៅបានដោយប្រសិទ្ធភាព និងជោគជ័យ ក៏អាស្រ័យដោយមាន

ការដឹកនាំ ប្រកបដោយភាពឈ្លាសវៃ និងប៉ិនប្រសព្វ របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដែលតែងតែគាំទ្រវាល់សកម្មភាពការងារ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ ម៉្យាងទៀតជោគជ័យខាងលើក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋានទាំងស្ថាប័នរដ្ឋ ស្ថាប័នមិនមែនរដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

យើងសង្ឃឹមថា ក្នុងឆ្នាំ២០១៩ ខាងមុខនេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង-ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ សហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង៕

# ឧបសម្ព័ន្ធ ទី ១. កម្មវិធីសន្និបាត

## កម្មវិធី

**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និង ទិសដៅការងារ ឆ្នាំ២០១៩**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**
ថ្ងៃព្រហស្បតិ៍១៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩

| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី/ថ្នាក់ដឹកនាំ** |
|---|---|---|
| **ពេលព្រឹក** | | |
| ៧:៣០- ៨:០០ | សមាជិក សមាជិកា សន្និបាតមកដល់ និងចុះឈ្មោះ | |
| ៨:០០- ៨:៣០ | ថ្នាក់ដឹកនាំ ភ្ញៀវកិត្តិយស និងសមាជិក នៃអង្គសន្និបាតអញ្ជើញដល់ | |
| ៨:៣០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ៨:៣០- ៩:១៥ | **ពិធីបើកសន្និបាត**<br>- ប្រកាសហេតុ(គណៈអធិបតី និងសមាជិកសន្និបាត)<br>- គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា<br>- សុន្ទរកថាបើកសន្និបាតដោយ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>- អានរបាយការណ៍សង្ខេបស្តីពីលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩របស់ក្រសួងទរពអ ដោយ **ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ** រដ្ឋលេខាធិការ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**<br>ឯកឧត្តម ឆេង សារឿន<br>ឯកឧត្តម កង ណែម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថារី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ<br>តំណាងជាន់ខ្ពស់ក្រសួង-ស្ថាប័ន |
| ៩:១៥- ៩:៣០ | សម្រាក ពិសាភេសជ្ជៈនិងអាហារសម្រន់ | |
| ៩:៣០-១១:០០<br><br>១១:០០-១២:០០ | - កិច្ចប្រជុំពេញអង្គ (បទអន្តរាគមន៍ របស់តំណាងក្រសួង ស្ថាប័ន ថ្នាក់ដឹកនាំ រាជធានី-ខេត្ត និងតំណាងមន្ទីរទរពអ រាជធានី-ខេត្ត និងពិភាក្សាលើរបាយការណ៍ក្រសួង និង សំណួរផ្សេងៗ)<br>- ពិភាក្សាលើបទអន្តរាគមន៍ និងបកស្រាយចម្លើយ | ឯកឧត្តម ឆេង សារឿន (ប្រធាន)<br>ឯកឧត្តម កង ណែម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថារី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ |

| | | |
|---|---|---|
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ Buffet នៅសណ្ឋាគារ | |
| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី/ថ្នាក់ដឹកនាំ** |
| **ពេលរសៀល** | | |
| ១៣:៣០-១៤:៣០ | ពិភាក្សាតាមក្រុម (បែងចែកជា ៣ ក្រុម) លើរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩ ដោយផ្តោតលើប្រធានបទ៣ ដូចខាងក្រោម៖ | |
| | ក្រុមទី១៖ "ការប្រឈមក្នុងការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា" | ឯកឧត្តម កង ណៃម (ប្រធានក្រុម)<br>លោកជំទាវ សុខ វិឡាយ<br>អនុរដ្ឋលេខាធិការ<br>អគ្គនាយក និងសមាសភាពផ្សេងទៀត (ដូចមានក្នុងតារាងបែងចែក) |
| | ក្រុមទី២៖ "ការប្រឈមក្នុងការងារ អធិការកិច្ច" | ឯកឧត្តម ឆេង សារឿន (ប្រធានក្រុម)<br>ឯកឧត្តម ឌុច សុវណ្ណារី<br>ឯកឧត្តម ថាច់ ឃន<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>អនុរដ្ឋលេខាធិការ<br>អគ្គនាយក និងសមាសភាពផ្សេងទៀត (ដូចមានក្នុងតារាងបែងចែក) |
| | ក្រុមទី៣៖ "ការប្រឈមក្នុងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់" | ឯកឧត្តម បណ្ឌិត ចាប សុថារិទ្ធ (ប្រធានក្រុម)<br>លោកជំទាវ សុភ័ក្ត ថាវី<br>អនុរដ្ឋលេខាធិការ<br>អគ្គនាយក និងសមាសភាពផ្សេងទៀត (ដូចមានក្នុងតារាងបែងចែក) |
| ១៤:៣០-១៥:១៥ | -ក្រុមនីមួយៗរាយការណ៍ពីលទ្ធផលតាមក្រុម (មួយក្រុមៗមានរយៈពេល១០នាទី) | ឯកឧត្តម ឆេង សារឿន (ប្រធាន)<br>ឯកឧត្តម កង ណៃម<br>ឯកឧត្តម ថាច់ ឃន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថាវី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ |
| ១៥:១៥-១៥:៣០ | សម្រាក ពិសាភេសជ្ជៈនិងអាហារសម្រន់ | |

| | | |
|---|---|---|
| ១៥:៣០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ១៥:៣០-១៦:៤៥ | **ពិធីបិទសន្និបាត**<br>-អានរបាយការណ៍បូកសរុបលទ្ធផលនៃអង្គសន្និបាតដោយ **ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ** រដ្ឋលេខាធិការ<br>-សុន្ទរកថាបិទសន្និបាតដោយ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ពិធីបំពាក់គ្រឿងឥស្សរិយយសជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ<br>-បិទកម្មវិធី។ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>ឯកឧត្តម ឆេង សារឿន<br>ឯកឧត្តម កង ណៃម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត្រ ថាវី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ<br>តំណាងជាន់ខ្ពស់ក្រសួង-ស្ថាប័ន |
| ១៧:៣០-២២:៣០ | -ពិធីជប់លៀងអាហារសាមគ្គី(ភោជនីយដ្ឋាន**ចឹងមាស**) (ថ្នាក់ដឹកនាំ សមាជិក សមាជិកាសន្និបាតទាំងអស់ចូលរួម)<br>-កម្មវិធីកំសាន្ត (មានការប្រគុំតន្ត្រី ការរាំលេងកំសាន្ត និងចាប់ឆ្នោតយករង្វាន់)។ | |

***កំណត់សំគាល់៖***

១) គណៈកម្មាធិការ រៀបចំសន្និបាត សូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់។

២) សម្លៀកបំពាក់៖ បុរស៖ អាវធំ នារី៖ ប្រពៃណី។

៣) សូមប្រាប់មុន (Confirm) ចំពោះការចូលរួមជប់លៀងពេលល្ងាច ទី៤ ខែមេសា ឆ្នាំ ២០១៩ ដល់ក្រុមលេខាធិការដ្ឋានរៀបចំសន្និបាត ដើម្បីងាយស្រួលដល់ការរៀបចំ និងចៀសវាងការខ្វះខាតយថវិកា។

៤) ពិធីជប់លៀងត្រូវបានប្រារព្ធឡើងដោយសារការចូលរិភាគទានដោយស្ម័គ្រចិត្តពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង

៥) សូមទាក់ទងទូរស័ព្ទ ឯកឧត្តម គឹម សុខជា៖ ០១៧៤៦៩៦៩៩ និង លោក ស្រ៊ុន សារ៉េន៖ ០៨៩៧២៩២៩២

# ឧបសម្ព័ន្ធ ទី ២. របាយការណ៍សង្ខេបលទ្ធផលការងារ ២០១៨ និងទិសដៅ ២០១៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**
**និងអធិការកិច្ច**

**របាយការណ៍សង្ខេប**
**ស្តីពី**
**ការបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

## ក. សេចក្តីផ្តើម

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការងារចំបង គឺការធ្វើទំនាក់ទំនង សម្របសម្រួលការងាររវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ច លើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និង បាតុភាពអសកម្មនានាដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធរបស់ប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ក្នុងឆ្នាំ២០១៨ នេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានសម្រេចនូវសមិទ្ធផលនានា ជាច្រើនដូចរៀបរាប់ខាងក្រោម។

# ខ. សមិទ្ធផលការងារ

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១.១. រដ្ឋបាល

-ទទួលលិខិតចូល និងបញ្ជូនលិខិតចេញ រៀបចំតាំងបដាពាក្យស្លោកគ្រប់ពិធីបុណ្យជាតិ-អន្តរជាតិ គ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-រៀបចំសារលិខិតថ្វាយព្រះពរ ជូនពរដល់ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា និងធ្វើសារលិខិតជូនពរថ្នាក់ដឹកនាំកំពូលៗ របស់ជាតិ ធ្វើសេចក្តីសម្រេច សេចក្តីជូនដំណឹង លិខិតបង្គាប់ការ លិខិតអញ្ជើញ វិញ្ញាបនបត្ររដ្ឋបាល អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ និងលិខិតរដ្ឋបាលផ្សេងៗ បញ្ជូនទៅក្រសួង ស្ថាប័ននានា បានចុះពង្រឹងការងាររដ្ឋបាល នៅគ្រប់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី ខេត្ត។

-បូកសរុបរបាយការណ៍ របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំសម្រាប់ជូនទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមសិក្ខាសាលា ការចុះសួរសុខទុក្ខ កងកម្លាំងការពារព្រំដែនកម្ពុជា-ថៃ ពិធីប្រកាសចូលកាន់មុខតំណែងប្រធានមន្ទីរ និងពិធីបុណ្យជាតិនៅតាមបណ្តា រាជធានី ខេត្តមួយចំនួន និងបានចូលរួមទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បណ្តាប្រទេសនានា ដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា។

### ១.២. បុគ្គលិក និងធនធានមនុស្ស

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារផ្សេងៗ បានធ្វើប្រកាសស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន៤៨ រូប បានធ្វើប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការចំនួន៦រូបចេញពីក្របខ័ណ្ឌក្រសួង និងបានធ្វើប្រកាសស្តីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការចំនួន ៤រូប មកពីក្របខ័ណ្ឌក្រសួងផ្សេង ឱ្យមកបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង។

-ធ្វើប្រកាសស្តីពីការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការថ្មីចំនួន ៦៦រូប ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង និងដាក់ឱ្យធ្វើកម្មសិក្សាសាកល្បងក្នុងក្របខ័ណ្ឌរយៈពេល១២ខែ។

-ធ្វើប្រកាសស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន២រូប ក្នុងអង្គភាព ក្រោមឱវាទក្រសួង។

-ធ្វើប្រកាសស្តីពីការលុបឈ្មោះ និងក្របខ័ណ្ឌមន្ត្រីរាជការចំនួន១រូប ដែលទទួលមរណភាព។

-ធ្វើប្រកាសស្តីពីការផ្លាស់ប្តូរមន្ត្រីជាប់កិច្ចសន្យាចំនួន២០រូប នៅទីស្តីការក្រសួង។

-ធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចំនួន១រូប ចូលបម្រើការងារវិញ។

### ១.៣. ការបណ្តុះបណ្តាល

ចាត់បញ្ជូនមន្ត្រីរាជការចំនួន១០៩រូប ទៅបណ្តុះបណ្តាលជំនាញផ្សេងៗ នៅក្នុងប្រទេស និងក្រៅប្រទេស ក្នុងនោះចំនួន២០រូប ជំនាញអធិការកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងចំនួន៣រូបជំនាញ ភាសាចិន នៅសាធារណរដ្ឋប្រជាមានិតចិន។

### ១.៤. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-កែសម្រួលក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងបង្កើតលេខាធិការដ្ឋាន នៃក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្រសួង។ ក្រុមការងារបានបំពេញភារកិច្ចយ៉ាងសកម្ម ជាពិសេសក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលេខាធិការដ្ឋាន នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើការជាមួយក្រុមការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដែលប្រព័ន្ធនោះនឹងត្រូវតម្លើងនៅក្រសួងនៅឆ្នាំ២០២០។

## ១.៥. ផែនការ និងស្ថិតិ

-រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០១៩-២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើទៅក្រសួងផែនការ។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកា២០១៩-២០២១ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញ ២៥ រាជធានី-ខេត្ត នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-រៀបចំគម្រោងផែនការថវិកា ប្រចាំឆ្នាំ២០១៩ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញ ២៥ រាជធានី-ខេត្ត នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបានចូលរួមកិច្ចប្រជុំចរចារកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំក្រសួង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ (ផយអជ) ផ្ញើជូនក្រសួងផែនការ។

-ចំរបាយកាណ៍ស្តីពីស្ថិតិផ្លូវការមានការចាត់តាំងរួមមាន៖ ការអនុម័តច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ផ្ញើជូនក្រសួងផែនការ។

-ប្រមូល និងបញ្ចូលទិន្នន័យតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ តាមអគ្គនាយកដ្ឋានទាំង៣ នៃទីស្តីការក្រសួង និងតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ចូលរួមសិក្ខាសាលាជាច្រើនលើក ស្តីពីការពិគ្រោះយោបល់ ការផ្សព្វផ្សាយ ពីគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

-ចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស លើការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈសម្រាប់មន្ត្រីគ្រប់គ្រង ហិរញ្ញវត្ថុ និងមន្ត្រីគ្រប់គ្រងថវិកា។

## ១.៦. សហប្រតិបត្តិការអន្តរជាតិ

ក្រសួងបានសម្រេចការងារដូចខាងក្រោម៖

-ថ្នាក់ដឹកនាំក្រសួងបានទទួលជួបសវនាការការងារជាមួយ ១) លោកជំទាវ **ម៉ានីកា ចេន** (Manika Jain) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ២) ឯកឧត្តម **វូ ក្វាងមិញ** (Vu Quang Minh) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា ៣) ឯកឧត្តម **ហ៊្សុង ប៉ូ** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានបញ្ចប់អាណត្តិការទូតនៅកម្ពុជា ៤) គណៈប្រតិភូ អាជ្ញាធរអធិការកិច្ចរដ្ឋ និងប្រឆាំងអំពើពុករលួយ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៥) គណៈប្រតិភូដែលដឹកនាំដោយឯកឧត្តមបណ្ឌិត **ខាំផេង សាយស៊ុមផេង** រដ្ឋមន្ត្រីក្រសួងការងារ និងសុខុមាលភាពសង្គម នៃសាធារណរដ្ឋ

ប្រជាធិបតេយ្យ ប្រជាមានិតឡាវ ៦) គណៈប្រតិភូសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ដឹកនាំដោយឯកឧត្តម **ហាវ អាឡេញ** (HAV A LENH) អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការរណសិរ្សមាតុភូមិវៀតណាម ៦) ឯកឧត្តម **ប៉ាន់យ៉ារ៉ាក់ ភូនធប់ (Panyarak PoonThup)** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃ ៧) លោក **អេដវើដ វីលសឹន** (EDWARD WILSON) ចៅហ្វាយក្រុង SIGNAL HILL សហរដ្ឋអាមេរិក ៨) ឯកឧត្តម **ហើ ជុនកើ** (HE JUNKE) ប្រធានសហព័ន្ធយុវជន ទូទាំងប្រទេសចិន និង ៩) គណៈប្រតិភូសមាគមមិត្តភាពវៀតណាម-កម្ពុជា ដឹកនាំដោយលោក **ង៉ូ ម៉ៅ** ប្រធានសមាគម នៅទីស្តីការក្រសួង។

-អញ្ជើញឯកអគ្គរដ្ឋទូត សាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិតសភាកម្ពុជា ដើម្បីចូលរួមពិធីប្រគល់វិញ្ញាបនបត្រដល់សិក្ខាកាមជាមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានរៀនភាសាចិនកម្រិតបឋម។

-សម្របសម្រួលចាត់បញ្ជូនគណៈប្រតិភូ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ទៅទស្សនកិច្ច នៅវៀតណាម ដើម្បីចូលរួមប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាមលើកទី១៦ (JC) នៅទីក្រុងហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ចាត់បញ្ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ២០រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចរយៈពេល១ខែ នៅទីក្រុងហាណូយ។

-សម្របសម្រួល ជូនឯកឧត្តម ប៉ែន ច័ន្ទសុខរិន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅចូលរួមទស្សនកិច្ចសិក្សាស្វែងយល់ពីបទពិសោធន៍ក្នុងការផ្តល់សេវាសាធារណៈ នៅវិទ្យាស្ថានបណ្តុះបណ្តាលមន្ត្រីរាជការ របស់ប្រទេសសឹង្ហបុរី។

## ២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១. នីតិកម្ម

-ចូលរួមរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន១១លើក។

-ចូលរួមរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាន និងនីតិវិធី នៃអធិការកិច្ចហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន៤លើក។

-ចូលរួមកិច្ចប្រជុំអន្តរក្រសួងចំនួន៤លើក។

-ចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណីស្តីពីកាតព្វកិច្ចចំនួន១លើក

-ចុះស្ទង់មតិប្រជាពលរដ្ឋស្តីពីការយល់ដឹងលើច្បាប់ភូមិបាលចំនួន១៤លើក គឺខេត្តស្វាយរៀងចំនួន៤លើក ពោធិ៍សាត់ចំនួន២លើក សៀមរាបចំនួន២លើក កំពង់ធំចំនួន២លើក ព្រះសីហនុចំនួន២លើក និងខេត្តកែបចំនួន២លើក ដោយមានប្រជាពលរដ្ឋចូលរួមចំនួន១ ៦៩៧នាក់ (ស្ត្រីចំនួន៩១៣នាក់)។

### ២.២. ការអប់រំ ផ្សព្វផ្សាយច្បាប់

-បានចុះផ្សព្វផ្សាយច្បាប់ចំនួន១២៧លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាចំនួន ២២លើក និងមន្ទីររាជធានី-ខេត្តចំនួន១០៥លើក) គឺ ១) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ៣) ច្បាប់ស្តីពីការបង្ការនិងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/

ជំងឺអេដស៍ ៤) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និង ៥) ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង នៅខេត្តជាច្រើន ដោយមានអ្នកចូលរួមចំនួន៣៣ ៥៧៤នាក់ (ស្ត្រីចំនួន១៤.២៦៥នាក់) និងបានទទួលសំណួរចំនួន២.៥៨៨សំណួរ ព្រមទាំងបានឆ្លើយជូនដល់ម្ចាស់សំណួរ។

-បានចុះសិក្សាស្រាវជ្រាវអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋ មុនការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៅឃុំត្រពាំងរាំង និងឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរចំនួន៨៩នាក់ (ស្ត្រីចំនួន៤៥នាក់) ក្នុងនោះប្រជាពលរដ្ឋមានចំនួន៤ភូមិស្មើនឹង៨០នាក់ និងអាជ្ញាធរពាក់ព័ន្ធចំនួន៩នាក់។

## ២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន១លើក សេចក្តីព្រាងច្បាប់ចំនួន១៥លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៥លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន១លើក។

## ២.៤. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា លើសេចក្តីស្នើច្បាប់ចំនួន១លើក សេចក្តីព្រាងច្បាប់ចំនួន២០លើក ការបោះឆ្នោតជ្រើសតាំងចំនួន២លើក ព្រះរាជសារចំនួន២លើក របាយការណ៍របស់រដ្ឋសភាចំនួន១លើក ការអនុម័តបទបញ្ជាផ្ទៃក្នុងរដ្ឋសភានីតិកាលទី៦ចំនួន១លើក ចូលរួមអមដំណើរជាមួយគណៈកម្មការទី៦ចំនួន១លើក និងចូលរួមអមដំណើរជាមួយគណៈកម្មការទី៨ចំនួន១លើក។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភាលើសេចក្តីព្រាងច្បាប់ចំនួន១៦លើក។

## ២.៥. ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

រៀបចំវេទិកាសាធារណៈ ដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន១០លើក នៅខេត្តកំពង់ចាមចំនួន២លើក ខេត្តពោធិ៍សាត់ចំនួន២លើក ខេត្តកំពង់ឆ្នាំងចំនួន២លើក ខេត្តព្រៃវែងចំនួន២លើក និងខេត្តកំពង់ស្ពឺចំនួន២លើក ដោយមានអ្នកចូលរួមចំនួន២.២០៨នាក់ (ស្ត្រីចំនួន៨៥៨នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន៥៤២សំណូមពរ។

# ៣. អធិការកិច្ច

## ៣.១. អធិការកិច្ច (វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)

ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៦ និង២០១៧ នៅក្រសួងចំនួន១៥ (វិស័យសេដ្ឋកិច្ចចំនួន៧ក្រសួង វិស័យរដ្ឋបាលទូទៅចំនួន៤ក្រសួង ស្ថាប័ន និងវិស័យសង្គមកិច្ចចំនួន៤ក្រសួង) និងនៅតាមបណ្តារាជធានី ខេត្តសរុបចំនួន៦៣៤មន្ទីរ អង្គភាព (វិស័យសេដ្ឋកិច្ចចំនួន២៩៥មន្ទីរ អង្គភាព វិស័យរដ្ឋបាលទូទៅចំនួន១៣២មន្ទីរ អង្គភាព និងវិស័យសង្គមកិច្ចចំនួន២០៧មន្ទីរ អង្គភាព)។

## ៣.២. ការតាមដានការអនុវត្តច្បាប់

ចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានានៅតាមបណ្តារាជធានីខេត្តចំនួន១៨ សរុបចំនួន២៩លើក ក្នុងនោះការងារកំពុងបន្តចុះតាមដានមានចំនួន ២ករណី ការងារ

ដែលបានបញ្ចប់មានចំនួន២៧ករណី រួមមានៈ (១) ច្បាប់ស្តីពីព្រៃឈើ (២) ច្បាប់ស្តីពីជលផល (៣) ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (៤) ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង (៥) ច្បាប់ស្តីពីការងារ (៦) អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ (៧) អនុក្រឹត្យ លេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ (៨) ប្រកាសលេខ២៤៧ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងអាជីវកម្មល្បែងកំសាន្ត ស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (៩) ការអនុវត្តកិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី។

### ៣.៣. ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន៩២បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៣៤បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៥៨បណ្តឹង)ៈ

-ពាក្យបណ្តឹងកំពុងពិនិត្យចំនួន៥បណ្តឹង។

-ពាក្យបណ្តឹងកំពុងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន២បណ្តឹង។

-ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន១៤បណ្តឹង។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួងចំនួន៨បណ្តឹង និងសមត្ថកិច្ចមន្ទីររាជធានី-ខេត្តចំនួន៥៨បណ្តឹង។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការចំនួន២បណ្តឹង។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្តចំនួន១បណ្តឹង។

-ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន៤០បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៣បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១៧បណ្តឹង)។

-ពាក្យបណ្តឹងបានដោះស្រាយចប់ចំនួន២២បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២០បណ្តឹង)។

## ៤. វិទ្យាស្ថានជាតិអធិការកិច្ច

-ប្រជុំពិភាក្សា និងណែនាំអំពីការធ្វើផែនការសកម្មភាព ឆ្នាំ២០១៩ របស់វិទ្យាស្ថាន ចំនួន ៨ លើក និងបានប្រជុំណែនាំអំពីការធ្វើផែនការថវិការបស់ការិយាល័យចំណុះវិទ្យាស្ថាន ចំនួន ៦លើក។

-ចូលរួមប្រជុំ និងទទួលការណែនាំពីការការពារកញ្ចប់ថវិការបស់វិទ្យាស្ថានជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃអង្គារ ទី៣១ ខែកក្កដា ឆ្នាំ២០១៨។

-ប្រជុំពិភាក្សា និងណែនាំអំពីការរៀបចំខ្លឹមសារ ដើម្បីត្រៀមការពារកញ្ចប់ថវិកាឆ្នាំ ២០១៩ របស់វិទ្យាស្ថានជាតិអធិការកិច្ច និងបញ្ហាផ្សេងៗ ចំនួន២លើក។

-រៀបចំប្រកាសស្តីពីការប្រើប្រាស់ត្រា និងនិមិត្តសញ្ញារបស់វិទ្យាស្ថានជាតិអធិការកិច្ច បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ របស់វិទ្យាស្ថានជាតិអធិការកិច្ច ហើយថ្នាក់ដឹកនាំក្រសួងបានចុះហត្ថលេខាឯកភាពនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២៣ របស់វិទ្យាស្ថានជាតិអធិការកិច្ច ហើយថ្នាក់ ដឹកនាំក្រសួងបានចុះហត្ថលេខាឯកភាពនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។

-រៀបចំផែនការសកម្មភាពឆ្នាំ២០១៩របស់វិទ្យាស្ថានជាតិអធិការកិច្ច ហើយថ្នាក់ដឹកនាំក្រសួងបានចុះហត្ថលេខាឯកភាពនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។

-រៀបចំគម្រោងចំណាយថវិកាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-រៀបចំកម្មវិធីបណ្តុះបណ្តាលឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-ចេញសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចសម្រាប់ថ្នាក់ដឹកនាំវិទ្យាស្ថានជាតិអធិការកិច្ច។

-ចេញសេចក្តីសម្រេចចាត់តាំងមន្ត្រីថ្មីចំនួន ៦រូប ឲ្យទៅបម្រើការងារ តាមការិយាល័យនីមួយៗ ចំណុះ វិទ្យាស្ថានជាតិអធិការកិច្ច។

-ទំនាក់ទំនង និងបានបញ្ជូនមន្ត្រី០២របស់វិទ្យាស្ថានទៅចូលរួមវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងបណ្ណាល័យនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។

-ទំនាក់ទំនង និងបានទទួលសៀវភៅចម្រុះមុខវិជ្ជាចំនួន ៩៦ក្បាល ពីអង្គការខេប (KAPE)។

-បណ្តុះបណ្តាលវគ្គសិក្សាជំនាញអធិការកិច្ចបឋម ស្តីពី "មូលដ្ឋានគ្រឹះនៃការងារអធិការកិច្ច" ចំនួន ១ វគ្គ រយៈពេល ៥ថ្ងៃចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអធិការកិច្ច។

# ៥. សវនកម្មផ្ទៃក្នុង

-ចុះតាមដានអនុសាសន៍របស់សវនករក្នុងការិយបរិច្ឆេទ២០១៦ នៅតាមបណ្តាសវនដ្ឋានបានចំនួន១២មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពត ក្រចេះ កំពង់ចាម កែប កំពង់ឆ្នាំង កំពង់ធំ តាកែវ ត្បូងឃ្មុំ ប៉ៃលិន បាត់ដំបង សៀមរាប និងខេត្តពោធិ៍សាត់។

-ចុះធ្វើសវនកម្មផ្ទៃក្នុងការិយបរិច្ឆេទ២០១៧ នៅតាមទីសវនដ្ឋាន បានចំនួន១៦មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តតាកែវ ប៉ៃលិន បាត់ដំបង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រះសីហនុ កំពង់ឆ្នាំង កំពង់ចាម កោះកុង ព្រះវិហារ និងខេត្តស្ទឹងត្រែង។

-ធ្វើរបាយការណ៍ស្តីពីការចុះធ្វើសវនកម្ម នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ចខេត្តតាកែវ ប៉ៃលិន បាត់ដំបង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រះសីហនុ កំពង់ឆ្នាំង កំពង់ចាម កោះកុង ព្រះវិហារ និងខេត្តស្ទឹងត្រែង។

# ៦. ការងារផ្សេងទៀត

## ៦.១ យេនឌ័រ

-ក្នុងឱកាសទិវាអន្តរជាតិនារី៨មីនាឆ្នាំ២០១៨ សមាជិកក្រុមការងារបច្ចេកទេសយេនឌ័រចំនួន៣រូប បានចូលរួមក្រាបបង្គំគាល់ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ **នរោត្តម មុនិនាថ សីហនុ** និងចូលរួមសម្តែងការគួរសម

ជាមួយសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

-ក្រុមការងារបច្ចេកទេសយេនឌ័រ ចំនួន៥៤រូប បានចូលរួមអបអរសាទរខួបលើកទី១០៧ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ ក្រោមអធិបតីភាព សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពពិព័រណ៍កោះពេជ្រ។

-ចូលរួមកម្មវិធីខួបលើកទី១០៧ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ ក្រោមប្រធានបទ «ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព» ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី នៅទីស្តីការក្រសួង។

-ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួង ស្ថាប័ន រៀបចំដោយក្រសួងកិច្ចការនារី និងដៃគូរអភិវឌ្ឍន៍ ដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម បទពិសោធន៍ និងទិសដៅផែនការបន្តសម្រាប់អនុវត្តឆ្នាំ២០១៩ ស្តីពីការបញ្ជ្រាបយេនឌ័រ នៅខេត្តសៀមរាប។

ជាមួយលទ្ធផល និងស្នាដៃដែលសម្រេចបានខាងលើ ថ្នាក់ដឹកនាំ មន្ត្រីរាជការជាស្ត្រីចំនួន១២៥រូប ត្រូវទទួលបានការលើកទឹកចិត្តក្នុងការតម្លើងឋានៈតួនាទី និងទទួលបានគ្រឿងឥស្សរិយយសគ្រប់ប្រភេទពីរាជរដ្ឋាភិបាល ចំនួន២៨រូប ត្រូវបានបញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញ និងសមត្ថភាពថែមទៀតទាំងក្នុង និងក្រៅប្រទេសចំនួន ៣៣រូប។

## ៦.២. ការចងសម្ព័ន្ធមេត្រីភាព

កាលពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៨ ដោយសហការជាមួយក្រុមហ៊ុនម៉ុង ឬទ្ធីគ្រុប ក្រុមហ៊ុនគូហ៊្វឡុង និងបណ្តាសប្បុរសជន រួមទាំងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការ គណៈប្រតិភូនដឹកនាំដោយលោកជំទាវ កិត្តិសង្គហបណ្ឌិត បានចុះជួបសំណេះសំណាលជាមួយកងកម្លាំងប្រដាប់អាវុធអង្គភាពនគរបាលជាតិ វរសេនាតូចលេខ៨២៧ និងវរសេនាតូចលេខ២៦៩ ឈរជើងក្នុងភូមិសាស្ត្រខេត្តកោះកុង ដោយបាននាំយកថវិកា និងអំណោយជាគ្រឿងឧបភោគ បរិភោគចែកជូនដល់អង្គភាពទាំងពីរសរុបថវិកាចំនួន១១៤.៧៩៧.០០០រៀល (មួយរយដប់បួនលានប្រាំពីររយកៅសិបប្រាំពីរពាន់រៀល)។

## ៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន

ក្រសួងបានបង្កើតក្រុមការងារគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានក្រសួង។ ក្រុមការងារបានប្រជុំជាច្រើនលើក ដើម្បីធ្វើផែនការ និងរៀបចំកសាងគេហទំព័រថ្មីរបស់ក្រសួង ធ្វើបច្ចុប្បន្នភាពព័ត៌មាន និងតម្លើងកម្មវិធីថ្មី (Application) សម្រាប់ដាក់ពាក្យបណ្តឹងអនឡាញ និងអ៊ីបណ្ណាល័យ។

## ៦.៤. អ្នកនាំពាក្យក្រសួង

ក្រសួងបានបង្កើតអ្នកនាំពាក្យ ដើម្បីបំពេញការងារប្រតិកម្មរហ័ស ឆ្លើយតបទៅនឹងព្រឹត្តិការណ៍សំខាន់ៗ របស់ក្រសួង និងបញ្ជូនព័ត៌មានទាន់ហេតុការណ៍នានា ដាក់ក្នុងបណ្តាញផ្សព្វផ្សាយ និងគេហទំព័រក្រសួង។

## គ. ការប្រឈម

-ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅមិនទាន់បានអនុម័តនៅឡើយ។

-ការអនុវត្តការងារតាមតួនាទីភារកិច្ចមិនទាន់បានល្អប្រសើរតាមឋានានុក្រម និងនីតិវិធីនៅឡើយ។

-នៅមានការលំបាក ក្នុងការចុះធ្វើបេសកកម្ម ដោយកង្វះថវិកាបុរេប្រទានគ្រប់គ្រាន់ និងខ្វះមធ្យោបាយធ្វើដំណើរ និងសម្ភារបច្ចេកវិទ្យាសម្រាប់ចុះបេសកកម្ម។

-សមត្ថភាពជំនាញរបស់មន្ត្រីអធិការកិច្ច ឬភ្នាក់ងារអធិការកិច្ចមួយចំនួននៅមានកម្រិតនៅឡើយ។

-ពុំទាន់មានដៃគូរអភិវឌ្ឍជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

-កិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង-ស្ថាប័ននៅមានកម្រិត។

-ចំនួនមន្ត្រីរាជការតិចតួចមិនទាន់ឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង។

-កិច្ចសហការរបស់អង្គភាពរងអធិការកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួននៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យឆ្លងប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច ចុះហត្ថលេខាយល់ព្រមលើលទ្ធផលអធិការកិច្ច។

## ឃ. ទិសដៅការងារបន្ត

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទីភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាពដូចខាងក្រោមៈ

### ១. រដ្ឋបាលកិច្ចការទូទៅ

#### ១.១. រដ្ឋបាល

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ និងឆាប់រហ័សទាន់ពេលវេលា។

-បន្តទំនាក់ទំនង និងសហការជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

#### ១.២. បុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ និងមន្ត្រីបាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

### ១.៣. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក តាមសកម្មភាព ចង្កោមសកម្មភាព អនុកម្មវិធី នៃកម្មវិធី ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់ការងារបៀវត្សដំណើរការរដ្ឋបាលទូទៅ និង បេសកកម្មក្នុងប្រទេស ។ល។

-ចុះកិច្ចបញ្ជិកាគណនេយ្យជាប្រចាំ និងគ្រប់គ្រងព័ត៌មានវិទ្យាសកម្មភាពហិរញ្ញវត្ថុ គ្រប់គ្រងចំណូល ចំណាយ ឱ្យបានសមស្រប។

-ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកាឱ្យសមស្របតាមគម្រោងថវិការដ្ឋ ប្រមូលផ្តុំតម្រូវការ និងសម្របសម្រួលរាល់ការចំណាយ។

-ត្រួតពិនិត្យបច្ចេកទេសក្នុងការអនុវត្តលទ្ធកម្មសាធារណៈ។

-គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវសន្និធិ។

-ទទួលបែងចែក និងជួសជុល សម្ភារ បរិក្ខារ ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួង។

-គ្រប់គ្រង និងបែងចែកប្រេងឥន្ធនៈឱ្យទាន់ពេល ជាពិសេសសម្រាប់ក្រុមបេសកកម្មចុះបំពេញភារកិច្ចតាមខេត្ត។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ។

### ១.៤. ផែនការ និងស្ថិតិ

-បន្តរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២០-២០២២របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើជូនក្រសួងផែនការ។

-បន្តចុះណែនាំលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ សម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី -ខេត្តទាំង២៥ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តរៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំ២០១៩ ទាំងរដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្តទាំង២៥ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច (ហើយចូលរួមកិច្ចប្រជុំចរចាកម្រិតបច្ចេកទេស និងចរចា កម្រិតថ្នាក់ដឹកនាំក្រសួង និងក្រសួង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

-បន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ (ផយអជ) ផ្ញើជូនក្រសួងផែនការ។

-បន្តរៀបចំសេចក្តីព្រាងផែនការសកម្មភាព ស្តីពីការអប់រំផ្សព្វផ្សាយច្បាប់ ឆ្នាំ២០២០-២០២២ សម្រាប់ជាធាតុចូលរួមចំណែកអនុវត្ត នៃគោលនយោបាយជាតិប្រជាជនឆ្នាំ ២០១៦-២០៣០។

-បន្តរៀបចំរបាយការណ៍ស្តីពីស្ថិតិផ្លូវការមានការចាត់តាំងរួមមានៈ ការអនុម័តច្បាប់ ការងារអប់រំផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ផ្ញើជូនក្រសួងផែនការ ទាន់ពេលវេលា។

### ១.៥. សហប្រតិបត្តិការអន្តរជាតិ

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យ នៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI)និងវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បង្កើនទំនាក់ទំនងជាមួយស្ថានទូតនៃព្រះរាជាណាចក្រថៃប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញការទំនាក់ទំនងកិច្ចសហប្រតិបត្តិការ រវាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជាមួយការិយាល័យទទួលពាក្យបណ្តឹង (OMBUDSMAN) នៃព្រះរាជាណាចក្រថៃ លើវិស័យអធិការកិច្ច។

## ២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១. នីតិកម្ម

-ចូលរួមរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

-ចុះស្ទង់មតិប្រជាពលរដ្ឋ នៅតាមបណ្តារាជធានី ខេត្ត។

-សិក្សាស្រាវជ្រាវ និងប្រមូលឯកសារច្បាប់ដែលពាក់ព័ន្ធ។

-រៀបចំសិក្ខាសាលាបំពាក់បំប៉នជំនាញស្ទង់មតិ និងបញ្ចូលទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ។

-រៀបចំបណ្ណាល័យអេឡិចត្រូនិច។

### ២.២. ការអប់រំផ្សព្វផ្សាយច្បាប់

-ទំនាក់ទំនងជាមួយបណ្តារាជធានី-ខេត្ត ដើម្បីចុះផ្សព្វផ្សាយច្បាប់។

-សិក្សាស្រាវជ្រាវឯកសារ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់។

-ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃមុន និងក្រោយការផ្សព្វផ្សាយច្បាប់។

-ចុះផ្សព្វផ្សាយច្បាប់នៅតាមបណ្តាខេត្តគោលដៅ។

### ២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួង និងតាមក្រសួង ស្ថាប័នតាមការអញ្ជើញ។

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងវិសាមញ្ញ នៅមន្ទីររដ្ឋសភា-ព្រឹទ្ធសភា។

-ចុះអមដំណើរជាមួយគណៈកម្មការនានានៃរដ្ឋសភា និងក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ។

-ចុះធ្វើវេទិកាសាធារណៈ។

## ៣. អធិការកិច្ច

### ៣.១. អធិការកិច្ច (លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និង សង្គមកិច្ច)

-ត្រៀមឆ្លងរបាយការណ៍ដែលបានបញ្ចប់ការចុះធ្វើអធិការកិច្ច លើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៧ និងបណ្ដាឆ្នាំពាក់ព័ន្ធ នៅក្រសួង និងតាមបណ្ដាមន្ទីរ-អង្គភាព ដែលនៅសេសសល់ក្នុងឆ្នាំ២០១៨។

-បន្តចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៧ និងបណ្ដាឆ្នាំពាក់ព័ន្ធ នៅក្រសួង និងបណ្ដាមន្ទីរ-អង្គភាព មួយចំនួនក្នុងរាជធានីភ្នំពេញដែលមិនទាន់ធ្វើចប់ក្នុងឆ្នាំ២០១៨។

-រៀបចំធ្វើសេចក្ដីជូនដំណឹងទៅបណ្ដាក្រសួង-ស្ថាប័នពាក់ព័ន្ធដែលនៅសេសសល់ពីឆ្នាំ២០១៨។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០១៩។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.២. ការតាមដានការអនុវត្តច្បាប់

-ត្រៀមឆ្លងរបាយការណ៍លទ្ធផលនៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលនៅសេសសល់ក្នុងឆ្នាំ២០១៨។

-ត្រៀមរៀបចំធ្វើសេចក្ដីជូនដំណឹងស្ដីពីការកែលម្អលើចំណុចខ្វះខាត ទៅតាមបណ្ដាក្រសួង-ស្ថាប័ន។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០១៩។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៣. ការទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ

-បន្តទទួលពាក្យបណ្ដឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្ដឹងក្នុងសារព័ត៌មានផងដែរ។

-រង់ចាំការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួង ដើម្បីជំរុញការអនុវត្តលទ្ធផលពាក្យបណ្ដឹង ដែលបានបញ្ជូនទៅគ្រប់ស្ថាប័ន និងបណ្ដារាជធានី-ខេត្តកន្លងមក។

-បន្តនឹងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្ដឹងដែលជាសមត្ថកិច្ចក្រសួង។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០១៩។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

## ៤. វិទ្យាស្ថានជាតិអធិការកិច្ច

-អភិវឌ្ឍស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រងស្នើសុំទីតាំងវិទ្យាស្ថាន អគារសិក្សា ការិយាល័យ និងសម្ភារបរិក្ខារ។

-ស្នើសុំបណ្ណាល័យ រោងពុម្ព និងសម្ភារបរិក្ខារ មធ្យោបាយធ្វើដំណើរសម្រាប់វិទ្យាស្ថាន។

-រៀបចំបង្កើតប្រព័ន្ធព័ត៌មានវិទ្យា និងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថានមួយច្បាស់លាស់។

-បង្កើតក្រុមប្រឹក្សាភិបាលសម្រាប់វិទ្យាស្ថាន និងគណៈកម្មការ រៀបចំខ្លឹមសារ កម្មវិធីបណ្ដុះបណ្ដាល។

-កសាងសមត្ថភាព ផ្នែកការស្រាវជ្រាវ និងភាពជាអ្នកដឹកនាំដល់មន្ត្រីវិទ្យាស្ថាន។

-ពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងហិរញ្ញវត្ថុ គ្រប់គ្រងការងារចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារ បរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន គ្រប់គ្រងការងារបុគ្គលិក ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ គ្រប់គ្រងការងារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

-ពង្រឹងការងារគ្រប់គ្រងផែនការ និងស្រាវជ្រាវ។

-រៀបចំ ចងក្រងសៀវភៅ ឯកសារ និងអត្ថបទនានាទាក់ទងនឹងជំនាញអធិការកិច្ច។

-បន្តផ្តល់ការបណ្តុះបណ្តាលជំនាញអធិការកិច្ចរយៈពេលខ្លី លើអធិការកិច្ចកម្រិតបឋម ដល់មន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

-ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសនានា ជាមួយអង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងជាមួយគ្រឹះស្ថានសិក្សា ផ្សេងៗដើម្បីអភិវឌ្ឍសមត្ថភាពវិទ្យាស្ថាន។

## ៥.សវនកម្មផ្ទៃក្នុង

បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន-ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៦. ការងារផ្សេងទៀត

### ៦.១. យេនឌ័រ

-រៀបចំសៀវភៅផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០១៨-២០២៣។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកាយេនឌ័រក្រសួងឆ្នាំ២០១៩ ស្របតាមផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

-រៀបចំអបអរសាទរខួបលើកទី១០៩ទិវាអន្តជាតិនារី៨មីនា ឆ្នាំ២០២០។

-ផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ អនុសាសន៍១២ចំណុចរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងអនុសាសន៍៦ចំនុច របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកិត្តិយសនៃគណៈកម្មការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ នៅក្រសួង និងនៅតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ជួបសំណេះសំណាលជាមួយមន្ត្រីរាជការដើម្បី «ស្វែងយល់ពីតម្រូវការ និងការប្រឈមរបស់មន្ត្រីរាជការស្ត្រីក្នុងក្រសួង»។

-ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។

-ផ្តល់វគ្គបំពាក់បំប៉នសមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំ។

-ពិនិត្យតាមដានការអនុវត្តការងារបញ្ជ្រាបយេឌ័រ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្ត។

**៦.២. ការចងសម្ព័ន្ធមេត្រីភាព**

ក្រសួង ដោយរួមសហការជាមួយ ក្រុមហ៊ុន ម៉ុង ឬទ្ធី គ្រុប និងក្រុមហ៊ុន គូ ហ៊ូឡុងបន្តចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាព ជាមួយកងវរសេនាតូចនគរបាលការពារព្រំដែនទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីរួមចំណែកថែរក្សាការពារបូរណភាពទឹកដីរបស់យើងឱ្យមានសុខសន្តិភាពជារៀងរហូត។

**៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន**

-ចាត់តាំងក្រុមការងារជំនាញអភិវឌ្ឍគេហទំព័រក្រសួង ធ្វើបច្ចុប្បន្នភាពជាប្រចាំ និងមានខ្លឹមសារគុណភាព សោភ័ណភាព និងសុវត្ថិភាពល្អជាងមុន។

-តម្លើង និងបញ្ចូលកម្មវិធី (Application) ថ្មី ដែលក្រុមការងារបានរៀបចំរួចជាស្រេចនូវកម្មវិធីថ្មីភ្ជាប់ក្នុងគេហទំព័រថ្មីរបស់ក្រសួង សម្រាប់ដាក់ និងទទួលពាក្យបណ្តឹងអនឡាញ និងអ៊ីបណ្ណាល័យ ដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងបានតាមរយៈទូរស័ព្ទដៃ ចូលក្នុងកម្មវិធីមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ផ្សេងៗបានយ៉ាងងាយ។

**៦.៣. អ្នកនាំពាក្យក្រសួង**

-ពង្រឹងការងារអ្នកនាំពាក្យក្រសួងថែមទៀត តាមរយៈបណ្តុះបណ្តាល បំពាក់មធ្យោបាយ បច្ចេកទេសផ្សេងៗដើម្បីអនុវត្តការផ្សព្វផ្សាយ និងបកស្រាយព័ត៌មានឱ្យទាន់ហេតុការណ៍។

# ខ. សេចក្តីសន្និដ្ឋាន

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានបំពេញការងារទៅតាមតួនាទីនិងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនប្រកបដោយប្រសិទ្ធភាព និងជោគជ័យ នៅឆ្នាំ២០១៨ និងមានទិសដៅការងារច្បាស់លាស់សម្រាប់ឆ្នាំ២០១៩។

កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារការប្រឹងប្រែងបំពេញការងាររបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់លោកជំទាវ កិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែនៅជិតស្និទ្ធជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួង និងកិច្ចសហការ និងគាំទ្រពីសំណាក់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជននានា។

លើសពីនេះ ក្រសួងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងជោគជ័យ អាស្រ័យដោយ មានការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយក រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែគាំទ្ររាល់សកម្មភាពការងាររបស់ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

# ឧបសម្ព័ន្ធ ទី ៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាត

## របាយការណ៍បូកសរុបលទ្ធផលសន្និបាត ឆ្នាំ ២០១៨-២០១៩
## របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

(អានដោយឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ)

សូមគោរពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** នាយករដ្ឋមន្ត្រី
ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋានទាំងបី
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូល ជាទីមេត្រី

ក្នុងរយៈពេលពេញមួយថ្ងៃនេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៨ និងលើកទិសដៅឆ្នាំ ២០១៩ ដែលបានបញ្ចប់នៅរសៀលថ្ងៃនេះ។

សន្និបាតដែលចូលរួម ដោយថ្នាក់ដឹកនាំក្រសួង ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ដែលមានអ្នកចូលរួមសរុបចំនួន ៦០៣ នាក់ បានប្រព្រឹត្តទៅដោយរលូនតាមកម្មវិធីដែលបានគ្រោងទុក។

នៅពេលព្រឹកបន្ទាប់ពី ខ្ញុំបានអានរបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៨ និងទិសដៅឆ្នាំ ២០១៩មក លោកជំទាវឧបនាយករដ្ឋមន្ត្រី បានថ្លែងសុន្ទរកថាបើកសន្និបាត ដោយបានបញ្ជាក់ពីប្រវត្តិសង្ខេបរបស់ក្រសួង និងតួនាទីភារកិច្ចរបស់ក្រសួង។ លោកជំទាវបានសម្តែងនូវមោទនភាព និងការកោតសរសើរ វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារ ផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។ លោកជំទាវក៏បានផ្តល់ការណែនាំ ដល់អង្គសន្និបាត ដើម្បីពិភាក្សាតាមក្រុម។

ក្រោយពីសម្រាកពិសាអាហារសំរន់ អង្គសន្និបាតបានធ្វើកិច្ចប្រជុំរួម (Planary Session) ដោយបើកទូលាយ ឱ្យមានការចូលរួមជាបទអន្តរាគមន៍ ជាយោបល់ និងសំណួរ ពីអង្គសន្និបាតទាំងមូល។ ជាការឆ្លើយតប គណៈអធិបតីដែលជារដ្ឋលេខាធិការក្រសួង សម្របសម្រួលដោយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឆេង សារឿន** បានកត់ត្រាជាធាតុចូល និងបានឆ្លើយតប ពន្យល់ និងបកស្រាយបានក្បោះក្បាយ។

ក្រោយពីសម្រាកពិសាបាយថ្ងៃត្រង់នៅសណ្ឋាគារសុខា នៅពេលរសៀលអង្គសន្និបាតបានបែងចែកអ្នកចូលរួមជាបីក្រុម លើប្រធានបទ ក្រុមទី១) "ការប្រឈមក្នុងការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងការផ្សព្វផ្សាយច្បាប់" ក្រុមទី២) "ការប្រឈមក្នុងការងារអធិការកិច្ច ដោះស្រាយពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់" និង ក្រុមទី៣) "ការប្រឈមក្នុងការងាររដ្ឋបាល ផែនការ ការបណ្តុះបណ្តាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់"។

ក្រោយពីពិភាក្សារួច ក្រុមនិមួយៗបាន លើកឡើងពីការប្រឈមដូចខាងក្រោម៖

ក្រុមទី១៖

- ខ្វះមធ្យោបាយធ្វើដំណើរ
- ប្រាក់បេសកកម្មនៅមានកំរិត
- សមត្ថភាពវិភាគនៃការស្នង់មតិនៅមានកំរិត
- ច្បាប់អធិការកិច្ចនៅមិនទាន់បានអនុម័ត ដោយសារក្រសួង ស្ថាប័នមួយចំនួន ជំទាស់នឹងបញ្ហាខ្លះដែលជាន់ភារកិច្ចគ្នា

ក្រុមទី២៖

- ខ្វះកិច្ចសហការ
- ជាន់ភារកិច្ចគ្នា
- កង្វះកិច្ចសហការពីស្ថាប័ន អង្គភាពរងអធិការកិច្ច
- ក្រុមការងារអនុវត្តក្រមសីលធម៌មិនទាន់បានត្រឹមត្រូវ
- កង្វះមធ្យោបាយធ្វើដំណើររួម
- ការដោះស្រាយពាក្យបណ្តឹងនៅមានការលំបាក ដោយកង្វះកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ និងកង្វះមធ្យោបាយ សម្ភារៈ

ក្រុមទី៣៖

- ការកែទម្រង់ផ្ទៃក្នុងនៅមានការលំបាក
- ចរន្តលិខិតចេញចូលនៅយឺតយ៉ាវ
- ការផ្សព្វផ្សាយព័ត៌នានាមាននៅមានភាពយឺតយ៉ាវ
- កង្វះការថែទាំ អនាម័យ និងសណ្តាប់ធ្នាប់
- វិន័យការងារនៅមានកំរិត
- មានអវត្តមានច្រើន

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និង មនសិការទទួលខុសត្រូវ ខ្ពស់ ក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នឯកជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

ក្នុងឆ្នាំ២០១៨-២០១៩ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់

បន្ថយឱ្យបានជា អតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

អង្គសន្និបាតទាំងមូលបានគាំទ្ររបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៨ និងទិសដៅឆ្នាំ ២០១៩ទាំងស្រុង ដោយមានសំណើខ្លះសុំកែសម្រួល អក្ខរាវិរុទ្ធ និងបំពេញបន្ថែមខ្លឹមសារខ្លះដែលក្រុមការងារនឹងធ្វើបច្ចុប្បន្នភាព រួចហើយនឹងដាក់បញ្ចូលក្នុងគេហទំព័រផ្លូវការ ក្រសួងតាមក្រោយ។

ជារួមសន្និបាតក្រសួងឆ្នាំនេះ ទទួលបានលទ្ធផលល្អគួរជាទីគាប់ចិត្ត ដោយអ្នកចូលរួមទាំងអស់ពេញចិត្ត យកចិត្តទុកដាក់ស្តាប់ និងចូលរួមជាយោបល់ល្អៗ និងមានសកម្មភាពរស់រវើក និងសកម្ម។ ជាលទ្ធផល ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់មានមោទនភាព និងប្តេជ្ញាចិត្តបំពេញការងារដ៏មានតម្លៃរបស់ខ្លួន ដើម្បីជាប្រយោជន៍ ដល់ការអភិវឌ្ឍន៍ស្ថាប័ន ការអភិវឌ្ឍសមត្ថភាព និងបង្កើនប្រសិទ្ធភាពការងារ ដើម្បីទទួលបានសមិទ្ធផល និងជោគជ័យថ្មីៗទៀតជូនរាជរដ្ឋាភិបាល។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំបាទមានកិត្តិយសសូមគោរពអញ្ជើញ លោកជំទាវកិត្តិសង្គហបណ្ឌិត មេត្តាឡើងថ្លែងសុន្ទរកថាបិទសន្និបាត សូមគោរពអញ្ជើញ។

# ឧបសម្ព័ន្ធទី ៤. សុន្ទរកថាបើកសន្និបាត

**សុន្ទរកថា**

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបើកសន្និបាតឆ្នាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ឆ្នាំ២០១៨-២០១៩
សណ្ឋាគារ សុខាភ្នំពេញ រាជធានីភ្នំពេញ, ថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៩

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយក្រៃលែង ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបើកសន្និបាតប្រចាំឆ្នាំ ២០១៨- ២០១៩ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ចនាពេលនេះ។ សន្និបាតនេះមានគោលបំណងត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០១៨កន្លងមក ដោយលើកឡើងពីការប្រឈមនានា និងផ្លាស់ប្តូរយោបល់ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ ហើយដាក់ចេញនូវវិធានការណ៍ និងទិសដៅថ្មីៗ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១៩ ដើម្បីសម្រេចបានលទ្ធផលដូចដែលក្រសួងបានដាក់ចេញ និងដើម្បីអនុវត្តតាមភារកិច្ច ផែនការ និងយុទ្ធសាស្ត្រដែលរាជរដ្ឋាភិបាលតម្រូវឱ្យក្រសួងបំពេញ។

ពិធីដ៏អធិកអធមនេះ មានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅ ថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត និងឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសដែលអញ្ជើញមកពីស្ថាប័នរដ្ឋផ្សេងៗជាច្រើនផងដែរ។ ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ និងសូមស្វាគមយ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលមានវត្តមាននាពេលនេះ។

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរ វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារ ផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !***

ខ្ញុំសូមរំលឹកបន្តិចអំពីប្រវត្តិរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ ក្រោយពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលចម្រុះ ក្នុងនីតិកាលទី ១ នៃរដ្ឋសភា (១៩៩៣-១៩៩៨) ស្ថាប័នទទួលបន្ទុកទំនាក់ទំនងរដ្ឋសភា និងស្ថាប័នទទួលបន្ទុកអធិការកិច្ច ជាស្ថាប័នពីរដាច់ពីគ្នា។ "រដ្ឋលេខា-ធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា" ជាស្ថាប័នមួយ និង "អគ្គលេខាធិការដ្ឋាន

អធិការកិច្ច" ជាស្ថាប័នមួយទៀត។ ស្ថាប័នទាំងពីរស្ថិតក្រោមចំណុះទីស្ដីការគណៈរដ្ឋមន្ត្រីដូចគ្នា។ ក្រោយមក នៅឆ្នាំ ១៩៩៩ ស្ថាប័នទាំងពីរខាងលើត្រូវបានច្របាច់បញ្ចូលគ្នាទៅជា "ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច" ដែលកំពុងដំណើរការរហូតមកដល់សព្វថ្ងៃ។

ក្រសួងមានភារកិច្ច ដឹកនាំគ្រប់គ្រង សម្របសម្រួល ធ្វើទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើអធិការកិច្ច លើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មចំបងរបស់ក្រសួង គឺតាមដានការអនុវត្តច្បាប់ ទប់ស្កាត់អំពើពុករលួយ ភាពអយុត្តិធម៌ក្នុងសង្គម និងការរំលោភបំពានដោយប្រើអំណាចដើម្បីបំរើប្រយោជន៍បុគ្គល និងបក្សពួក គ្រួសារ និងការពារសិទ្ធរបស់ពលរដ្ឋ ពោលគឺពង្រឹងអភិបាលកិច្ចល្អ ដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព របស់រាជរដ្ឋាភិបាលដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

ដូច្នេះ ការងារសំខាន់ទី ១ របស់ក្រសួងគឺ **ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** ដែលក្រសួងមានភារកិច្ចសម្របសម្រួល ធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា និងចូលរួមតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល លើកកម្ពស់ការយល់ដឹងពីច្បាប់ និងការអនុវត្តន៍ច្បាប់ ដោយធ្វើការផ្សព្វផ្សាយច្បាប់យ៉ាងទូលំទូលាយ ជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសឱ្យបានយល់ដឹង។ ក្រៅពីការងារខាងលើ ក្រុមការងារក្រសួងបានចុះទៅដល់គ្រប់ ខេត្ត ក្រុង ស្រុក ទីប្រជុំជន ជនបទដាច់ស្រយាល និងសហគមន៍នានា ដើម្បីបើកវេទិកាសាធារណៈ អប់រំ ផ្សព្វផ្សាយច្បាប់ ធ្វើការស្ទាបស្ទង់មតិ ដើម្បីស្វែងយល់ពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ ផ្សព្វផ្សាយរាល់អនុសាសន៍ ដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំ ពិសេសកម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជូនដល់ប្រជាពលរដ្ឋ ហើយពាំនាំនូវសំណូមពររបស់ប្រជាពលរដ្ឋ ជូនរាជរដ្ឋាភិបាលដើម្បីដោះស្រាយ។

ចំណែកការងារសំខាន់ទី២គឺ **ការងារអធិការកិច្ច** ដែលត្រូវអនុវត្តតាមស្ថាប័ន និងអង្គភាពនានាជាប្រចាំ ដែលនេះជាភារកិច្ចដ៏សំខាន់ទាក់ទងនឹងការពង្រឹងការអនុវត្តន៍ច្បាប់ សំដៅធានាប្រឆាំងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា នៅក្នុងជួររដ្ឋបាលសាធារណៈ ក៏ដូចជាផ្នែកមិនមែនរដ្ឋ ដើម្បីធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃថវិកា និងទ្រព្យសម្បត្តិរដ្ឋ ការពារសុវត្ថិភាពសាធារណៈ និងការពារសិទ្ធរបស់ប្រជាពលរដ្ឋ។

ក្រៅពីការងារខាងលើ ក្រសួងនៅមានភារកិច្ចច្រើនទៀត ដូចជាការតាមដានការអនុវត្តច្បាប់ ការទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ ដោះស្រាយពាក្យបណ្ដឹង និងបណ្ដុះបណ្ដាលជំនាញអធិការកិច្ចតាមរយៈវិទ្យាស្ថានជាតិអធិការកិច្ច។

ការធ្វើអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ គឺសំដៅទៅលើការទប់ស្កាត់អំពើពុករលួយ ព្រោះអំពើពុករលួយធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរណាស់ដល់ប្រទេសជាតិ ដូចជាបង្កការខាតបង់ថវិការដ្ឋ រាំងស្ទះដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច បង្កឧបសគ្គដល់ធុរកិច្ច និងការបាត់បង់ដល់ការប្រកួតប្រជែង ដោយសេរី និងយុត្តិធម៌ និងរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿមកលើរាជរដ្ឋាភិបាល។ ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវផ្ដោតទៅលើមធ្យោបាយជាសារវន្ត័ចំនួន ៣ គឺ៖ ការអប់រំបង្ការទប់ស្កាត់ជាមុន ការអនុវត្តច្បាប់ និងការចូលរួមពីមហាជន។ ដូច្នេះការងារ

អធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ មិនអាចផ្ដាច់ចេញពីការអប់រំផ្សព្វផ្សាយច្បាប់ជូនដល់មហាជន និងការចូលរួមរបស់ប្រជាជនបានឡើយ។

ចាប់តាំងពីការបង្កើតស្ថាប័ននេះមក ក្រសួងសម្រេចបានលទ្ធផលជាច្រើន ជាពិសេសក្នុងការងារស្នូលដូចជា អធិការកិច្ច ការទទួល និងដោះស្រាយពាក្យបណ្ដឹង (បណ្ដឹងតវ៉ា និងបណ្ដឹងបរិហារ) ការចុះស៊ើបអង្កេតករណីបណ្ដឹងពាក់ព័ន្ធទំនាស់ដីធ្លី ការសម្របសម្រួលបញ្ចប់ទំនាស់ពុំរ៉ៃ បានជាច្រើនករណី ការតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏មានភារកិច្ចធ្វើការអប់រំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អរ ជម្រុញលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាល ពីដំណាក់កាលទី១ ដល់ទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

*អង្គសន្និបាតទាំងមូលជាទីមេត្រី*

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានដាក់ចេញ នូវយុទ្ធសាស្ត្រចតុកោណ **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលមានបួនដំណាក់កាល។ដោយឡែក រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានប្រកាសដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយសម្រាប់ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិសម្រាប់រយៈពេល៥ឆ្នាំជាបន្តទៀត។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ មានអភិបាលកិច្ចល្អជាស្នូល និងមានមុំបួនគឺ ១) ការអភិវឌ្ឍន៍ធនធានមនុស្ស ២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច ៣) ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ន។ យុទ្ធសាស្ត្រថ្មីនេះបានពង្រីកនូវវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាពូបនីយកម្មមុំនីមួយៗ នៃចតុកោណយុទ្ធសាស្ត្រទាំង៤ ព្រមទាំងកែលម្អរបៀបវារៈ គោលនយោបាយ និងយន្តការអនុវត្តមួយចំនួនឲ្យកាន់តែល្អប្រសើរឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយ ក្នុងចក្ខុវិស័យប្រែក្លាយឋានៈរបស់ប្រទេសកម្ពុជា ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ព្រមទាំងនាំប្រទេសជាតិយើង ឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខ។

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលទើបនឹងបញ្ចប់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដែលនឹងត្រូវអនុម័ត ក្នុងឆ្នាំនេះ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយមានកំណត់នូវអាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ទៅតាមមុំ ឬវិស័យនីមួយៗ ដើម្បីទទួលបានជោគជ័យទៅតាមផែនការ។ លើសពីនេះទៀត

រាជរដ្ឋាភិបាលក៏បានត្រៀមលក្ខណៈជាស្រេច ដើម្បីធ្វើកំណែទម្រង់នានា ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីរាជការស៊ីវិល និងវិស័យឯកជន ដើម្បីទទួលបានផលចំណេញជាអតិបរិមា ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជា ទៅក្នុងសហគមសេដ្ឋកិច្ចអាស៊ាន ក្នុងតំបន់ផ្សេងទៀត និងក្នុងសកលលោក។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានសង្គតិភាពផងដែរ ជាមួយនឹងឯកសារគោលនយោបាយ តាមវិស័យដ៏ទៃទៀត របស់រាជរដ្ឋាភិបាល។ ដូច្នេះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺជាឯកសារមេគ្គុទ្ទេសក៏ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់រយៈពេលវែងសំដៅជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផល នៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទរបស់ជាតិ ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានរួមចំណែកក្នុងការអនុវត្ត យុទ្ធសាស្ត្រចតុកោណ សំដៅពង្រឹង អភិបាលកិច្ចល្អ និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយដែលពិតជា ស្របតាមគោលដៅយុទ្ធសាស្ត្រទី ៤ នៃ"**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" គឺ "បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបំរើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងស្ថានភាពអំណោយផលសម្រាប់វិនិយោគ។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ យើងពិតជាមានមោទនភាព និងអំណរសាទរ ចំពោះលទ្ធផលការងារគ្រប់ផ្នែក គ្រប់វិស័យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំសម្រេចបាន ហើយយើងប្តេជ្ញានឹងបន្តការងារឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

ជាការពិតណាស់ សមិទ្ធផលទាំងនេះ កើតឡើងចេញជាផ្លែផ្កាបាន ដោយសារការមានការដឹកនាំ និងចូលរួមរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងការគាំទ្រ និងកិច្ចសហការពីក្រសួង ស្ថាប័ន និងអង្គភាព នានា។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ដើម្បីសម្រេចបានជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដូចបានលើកឡើងខាងលើនេះ ទាមទារឱ្យមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងសមត្ថភាព និងគោរពច្បាប់ និងក្រមសីលធម៌មន្ត្រីរាជការ និងខិតខំបំពេញការងារទៅតាមការចាត់តាំង និងតួនាទីរបស់ខ្លួនគ្រប់ៗគ្នា។ ទន្ទឹមនេះ មន្ត្រីរាជការក៏ត្រូវមានលក្ខណៈសម្បត្តិថ្លៃថ្នូ ស័ក្តិសមជាអ្នកបម្រើដ៏ល្អ របស់ប្រជាជន ដោយផ្លាស់ប្តូរឥរិយាបទ ប្រែក្លាយខ្លួនទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូរអភិវឌ្ឍន៍ដែលអាចទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនប្រសិទ្ធផលសេវាកម្មសាធារណៈ។ ជាមួយនេះ មន្ត្រីរាជការក្រសួងទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ៖ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" ដែលយើងត្រូវចងចាំ កុំឲ្យភ្លេចខ្លួន។

ក្នុងឱកាសសន្និបាតរយៈពេលពេញមួយថ្ងៃនេះ ខ្ញុំសូមអំពាវនាវសូមឯកឧត្តម លោកជំទាវ លោក លោកស្រីដែលចូលរួមទាំងអស់មេត្តាបង្កើនស្មារតី យកចិត្តទុកដាក់ ប្រើប្រាស់រយៈពេលនៃការប្រជុំនេះ ជាពិសេស ក្នុងកិច្ចពិភាក្សាតាមក្រុម ដែលបានបែងចែកតាមវិស័យសំខាន់ៗទាំង បី គឺ ទី១) ការងារទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា ទី២) ការងារអធិការកិច្ច និងទី៣) ការងាររដ្ឋបាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៅពេលរសៀល ដើម្បីផ្លាស់ប្តូរបទពិសោធន៍ លើកឡើងពីចំណុចល្អៗ និងចំណុចមិនទាន់បានកែលម្អ បញ្ហាប្រឈមទាំងឡាយ ព្រមទាំងលើកនូវដំណោះស្រាយដ៏សមស្រប និងប្រកបដោយប្រសិទ្ធភាព ដើម្បីពិនិត្យសម្រេចដាក់ចុះទិសដៅ និងផែនការ សម្រាប់អនុវត្តបន្ត។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី និងសមាជិក សមាជិកា នៃអង្គសន្និបាត ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធី នាពេលនេះសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតឃ្លៀងឡើយ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យអង្គសន្និបាតសម្រេចបានជោគជ័យ និង**សូមប្រកាសបើកសន្និបាតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៨-២០១៩ចាប់ពីពេលនេះតទៅ។**

***សូមអរគុណ !***

# ឧបសម្ព័ន្ធទី ៥. សុន្ទរកថាបិទសន្និបាត

**សុន្ទរកថា**

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅ
ការងារសម្រាប់អនុវត្តឆ្នាំ២០១៩ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
សណ្ឋាគារ សុខាភ្នំពេញ រាជធានីភ្នំពេញ, ថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៩

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្ដីរីករាយក្រៃលែង ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំ ២០១៨-២០១៩ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនាពេលនេះ។ ក្នុងគោលបំណងបូកសរុបលទ្ធផលការងារដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០១៨កន្លងមក និងដាក់ចេញនូវទិសដៅថ្មីៗ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១៩ សន្និបាតដែលមានរយៈពេលពេញមួយថ្ងៃនេះ សម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលជាថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅ ថ្នាក់កណ្ដាល ទាំងថ្នាក់រាជធានី ខេត្ត និងឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសដែលអញ្ជើញមកពីក្រសួង ស្ថាប័ន រាជធានី ខេត្តផ្សេងៗដែលបានចូលរួមក្នុងសន្និបាតក្រសួងយើងខ្ញុំ។

ក្រោយពីដំណើរការពេញមួយថ្ងៃមក សន្និបាតយើង បានដំណើរការយ៉ាងរលូន និងទទួលបានការចូលរួមយ៉ាងសកម្ម រួមមានការពិភាក្សាតាមក្រុម ដោយលើកយកប្រធានបទតាមវិស័យចំបងៗ ក្នុងការងារក្រសួង និងលើកឡើងនូវបទពិសោធន៍ល្អៗ ការប្រឈមនានា និងដំណោះស្រាយ ប្រកបដោយភាពជាក់ស្ដែង និងលទ្ធភាពដែលមាន និងទទួលបាននូវលទ្ធផលជាផ្លែផ្កាគួរឱ្យកោតសរសើរ។

លទ្ធផលនេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ ពីស្មារតីសាមគ្គី និងការខិតខំបំពេញការងាររបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងរាជធានី-ខេត្ត ដែលបានខិតខំ ប្រឹងប្រែងបំពេញការងារ រួមគ្នាយ៉ាងសស្រាក់សស្រាំ រៀបចំ និងចូលរួមធ្វើបទបង្ហាញ ពិភាក្សា ផ្លាស់ប្ដូរយោបល់ល្អៗ ដោយប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ ការងារជាក់ស្ដែងក្នុងគោលបំណងស្វែងរកឲ្យឃើញបញ្ហាប្រឈម ហើយបានដាក់ចេញជាផែនការសកម្មភាពសម្រាប់អនាគត។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានប្រឹងប្រែងបំពេញភារកិច្ចស្នូលរបស់ខ្លួន ប្រកបដោយស្មារតី ទទួលខុសត្រូវខ្ពស់ មានក្រមសីលធម៌វិជ្ជាជីវៈ ទទួលបានលទ្ធផលគួរជាទីមោទនៈ ដើម្បីសម្រេចភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ នេះជា

មោទនភាព និងកិត្តិយសដ៏ធំធេង ដែលក្រសួងទទួលបានជោគជ័យលើការងារជាច្រើន ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួន។

ខ្ញុំសូមអបអរសាទរ និងគាំទ្ររបាយការណ៍សន្និបាត ដែលរួមមានការបូកសរុបសកម្មភាព ឆ្នាំ២០១៨ និងទិសដៅ សម្រាប់ឆ្នាំ២០១៩ ដែលអង្គសន្និបាតបានសម្រេច។

*អង្គពិធីទាំងមូលជាទីមេត្រី*

រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណ ដែលមានបួនដំណាក់កាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលទើបនឹងបញ្ចប់ និងត្រៀមអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្នុងឆ្នាំនេះ ដើម្បីអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ ដោយកំណត់អាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើកលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ដើម្បីទទួលបានជោគជ័យ។ លើសពីនេះទៀត រាជរដ្ឋាភិបាលក៏បានត្រៀមលក្ខណៈជាស្រេច ដើម្បីធ្វើកំណែទម្រង់នានា ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីរាជការស៊ីវិល និងវិស័យឯកជន ដើម្បីទទួលបានផលចំណេញជាអតិបរិមា ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជា ទៅក្នុងសហគមសេដ្ឋកិច្ចអាស៊ាន ក្នុងតំបន់ផ្សេងទៀត និងក្នុងសកលលោក។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានសង្គតិភាពផងដែរ ជាមួយនឹងឯកសារគោលនយោបាយ តាមវិស័យដ៏ទៃទៀត របស់រាជរដ្ឋាភិបាល។ ដូច្នេះយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិគឺជាឯកសារមេគ្គុទ្ទេសក៍ច្បាស់លាស់សម្រាប់តម្រង់ទិសសកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់រយៈពេលវែងសំដៅជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផល នៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទរបស់ជាតិ។

ជាគោលដៅយុទ្ធសាស្ត្រសម្រាប់អាណត្តិថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពទៅលើការកែទម្រង់អភិបាលកិច្ចសំដៅពង្រឹងស្ថាប័នសាធារណៈ និងកសាងរដ្ឋបាលស្អាតស្អំ ការវិនិយោគលើមូលធនមនុស្ស ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច និងការវិនិយោគ ព្រមទាំងការពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍជាមួយគ្រប់ដៃគូដែលមានការពាក់ព័ន្ធ ពិសេសការពង្រឹងសមត្ថភាពកម្ពុជាសម្រាប់សមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ដែលទាំងអស់នេះ នឹងធ្វើឱ្យប្រជាជនគ្រប់ៗរូបមានកម្រិតជីវភាពកាន់តែប្រសើរឡើងឥតឈប់ឈរ ហើយរស់នៅយ៉ាងសុខដុមរមនាក្នុងសង្គមកម្ពុជាមួយ ដែលគោរពគុណធម៌ តម្លៃមនុស្ស សេរីភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងយុត្តិធម៌សង្គម។

ដូចប្រសាសន៍សម្តេចតេជោ នាយករដ្ឋមន្ត្រីបានលើកឡើង រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវវិធានការមុតស្រួច និងជាក់ស្តែងនានា សំដៅពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា រួមមាន៖ កាត់បន្ថយថ្លៃឡូជីស្ទីក ជំរុញការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល កាត់បន្ថយថ្លៃអគ្គិសនី និងធានាស្ថិរភាព នៃការផ្គត់ផ្គង់ បន្តធ្វើសាមញ្ញកម្ម និងស្វ័យប្រវត្តិកម្មនីតិវិធីគយ កាត់បន្ថយចំណាយនៃការធ្វើធុរកិច្ចទាំងផ្លូវការ និងក្រៅផ្លូវការ ជំរុញការកែទម្រង់ និងទំនើបកម្មប្រព័ន្ធពន្ធ ដោយឈរលើគោលការណ៍យុត្តិធម៌ សមធម៌សេវាល្អ អភិបាលកិច្ចល្អ និងអនុលោមភាព និងជំរុញលើកកម្ពស់ការអប់រំបណ្តុះ

បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលក្នុងអាណត្តិថ្មីនេះ បានរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ តាមរយៈ ការរៀបចំបង្កើតមូលដ្ឋាន និងថ្នាលសម្រាប់ការពង្រីកផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍវិស័យឌីជីថល ទាំងផ្នែករឹង និងទន់ការរៀបចំអភិវឌ្ឍធនធានមនុស្ស និងជំនាញ ស្របតាមបរិការណ៍ថ្មីព្រមទាំងការបង្កើតក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិគាំទ្រដែលមានការពាក់ព័ន្ធ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនៅក្នុងដំណាក់កាលនៃការវិវត្តន៍វិស័យឌីជីថល និងដើម្បីបំរើសេវាកម្មឱ្យកាន់តែល្អប្រសើរជូនប្រជាពលរដ្ឋ ក្រសួងគ្រោងនឹងតម្លើងកម្មវិធីទទួលពាក្យបណ្តឹងអនឡាញ និងដាក់ឱ្យប្រើប្រាស់អ៊ីបណ្ណាល័យ ដែលប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្តឹង និងមើលឯកសារតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។

### *ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ និងសុវត្ថិភាពសាធារណៈ និងជម្រុញអភិបាលកិច្ចល្អ ប្រទេសជាច្រើនក្នុងពិភពលោក កំពុងប្រើប្រាស់យន្តការគ្រប់គ្រងវិស័យអធិការកិច្ច ដោយមានក្រសួង ឬស្ថាប័នទទួលបន្ទុកអធិការកិច្ច និងច្បាប់ស្តីពីអធិការកិច្ចដែលមានខ្លឹមសារ និងវិសាលភាពខុសៗគ្នា ទៅតាមស្ថានភាពជាក់ស្តែងនៃប្រទេសនិមួយៗ។

យន្តការ ជាស្ថាប័ន និងរចនាសម្ព័ន្ធចាត់តាំង ត្រូវដើរទន្ទឹមគ្នានឹងធនធានមនុស្ស ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីគ្រប់គ្រងវិស័យអធិការកិច្ច។ ប្រទេសខ្លះមានច្បាប់ស្តីពីអធិការកិច្ច តាមវិស័យជំនាញផ្សេងៗគ្នា ដូចជា៖ ច្បាប់អធិការកិច្ចលើទំនិញនាំចូល អធិការកិច្ចលើការដ្ឋានសំណង់ អធិការកិច្ចអចលនទ្រព្យ អធិការកិច្ចការងារ អធិការកិច្ចសុវត្ថិភាពចំណីអាហារ អធិការកិច្ចរោងចក្រ អធិការកិច្ចនេសាទ អធិការកិច្ចយានយន្ត អធិការកិច្ចគ្រឿងចក្រ អធិការកិច្ចគុណភាពអប់រំជាដើម។

ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីអធិការកិច្ច និងច្បាប់មួយចំនួនទៀតកំពុងស្ថិតនៅជាសេចក្តីព្រាង និងមិនទាន់ត្រូវបានអនុម័តនៅឡើយ។ ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់របស់ក្រសួង ពិតជាមានការលំបាកក្នុងការតាក់តែងច្បាប់ស្តីពីអធិការកិច្ច មានបញ្ហាប្រឈមជាច្រើនទាក់ទងនឹងធនធាន បច្ចេកទេស និងការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួន។

ទន្ទឹមនឹងនេះ ក្រសួងនៅមានការប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួនមិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ និងមានក្រសួង និងស្ថាប័នរដ្ឋមួយចំនួនមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នា ដូចជាគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ អគ្គាធិការ តាមក្រសួង និងក្រសួង ស្ថាប័នមួយចំនួនទៀត។ ម្យ៉ាងទៀត ការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះធ្វើបេសកកម្មអធិការកិច្ច ក៏នៅមានការខ្វះខាត និងជួបបញ្ហាខ្លះ។

ម៉្យាងទៀត ការងារអធិការកិច្ចជាការងារដែលលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ និងទាមទារសមត្ថភាព និងជំនាញច្បាស់លាស់ ពីបច្ចេកទេសអធិការកិច្ច និងសមត្ថភាពផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។

ទោះជាមានការប្រឈមខ្លះយ៉ាងណាក្តី ក្រសួងបានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ដោយទទួលខុសត្រូវក្នុងនាមរាជរដ្ឋាភិបាល ដែលបានប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងរាល់កិច្ចការសម្របសម្រួល និងធ្វើទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើការងារអធិការកិច្ច លើគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសម្រេចបានលទ្ធផលការងារជាច្រើន ដូចជាបានផ្សព្វផ្សាយច្បាប់ និងជាអប់រំ ដល់ប្រជាពលរដ្ឋ ជាពិសេសនៅតាមខេត្ត ស្រុក ទីប្រជុំជន និងជនបទនានាឱ្យគាត់បានយល់ដឹងពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗជាច្រើន។

ក្រសួងក៏បានចុះធ្វើអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍របស់ថ្នាក់ដឹកនាំ ដែលកាត់បន្ថយបាននូវការរំលោភដោយអំណាច អំពើពុករលួយ និងបាតុភាពអសកម្មនានា ដូចជាការអនុវត្តមិនត្រឹមត្រូវនៃច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសន្យារវាងក្រុមហ៊ុនឯកជនជាមួយរដ្ឋ ជួយកាត់បន្ថយ និងលុបបំបាត់ការកឹបកេងថវិកា និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅ និងជម្រុញប្រសិទ្ធភាពការងារ និងលើកស្ទួយអភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

លើសពីនេះទៀតក្រសួងបានទទួល និងដោះស្រាយពាក្យបណ្តឹងនានា ជាពិសេសបញ្ហាទំនាស់ដីធ្លី និងការងារសម្របសម្រួលបញ្ចប់ទំនាស់ពុំរ៉ៃ បានជាច្រើនករណី ដែលជួយសម្រាលបន្ទុករាជរដ្ឋាភិបាល និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ដោយផ្អែកតាមការពិភាក្សាក្នុងសន្និបាត និងដើម្បីឲ្យសម្រេចបាននូវគោលដៅដែលក្រសួងចង់បាន ខ្ញុំសូមស្នើ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ត្រូវ ផ្តោតលើអនុសាសន៍ដូចខាងក្រោមនេះ៖

១. ដោយសារការផ្សព្វផ្សាយច្បាប់ ជាតម្រូវការចាំបាច់ ក្រុមការងារក្រសួងត្រូវបន្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយគ្រប់២៥ រាជធានី-ខេត្ត ជាពិសេសទៅ តាមទីប្រជុំជន និងជនបទដាច់ស្រយ៉ាល និងជម្រុញការងារសិក្សាស្ទាបស្ទង់មតិ (Survey) ដោយបណ្តុះបណ្តាលពីវិធីសាស្ត្រ នៃការសិក្សាស្ទាបស្ទង់ និងការវិភាគទិន្នន័យដល់មន្ត្រីដែលពាក់ព័ន្ធ ដើម្បីធ្វើរបាយការណ៍ នៃលទ្ធផលដែលរកឃើញពីការស្ទាបស្ទង់ទាំងនោះ។

២. ត្រូវខិតខំបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចប់ផ្នែកសំខាន់ៗ នៃសេចក្តីព្រាងច្បាប់អធិការកិច្ច និងអនុក្រឹត្យដែលពាក់ព័ន្ធចំបងៗ។ ការងារសម្របសម្រួលនោះត្រូវការពារឱ្យបានជាអតិបរិមា នូវតួនាទី ភារកិច្ចស្នូលរបស់ក្រសួង ស្របតាមច្បាប់ដែលអនុញ្ញាត។

៣. ត្រូវរៀបចំ និងតម្លើងកម្មវិធី ទទួលពាក្យបណ្តឹងអនឡាញ និងបណ្ណាល័យ អេឡិចត្រូនិក (e-Library) ដែលតាមរយៈកម្មវិធីទាំងនោះ ប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្តឹង និងអាចមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។ ការអនុវត្តកម្មវិធីគឺជាការសម្រួលការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៤. ត្រូវពង្រឹងប្រសិទ្ធភាព ក្នុងបេសកកម្មចុះធ្វើអធិការកិច្ច ការអង្កេត ស្រាវជ្រាវពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់ តាមរយៈការរកព័ត៌មានឲ្យមានតុល្យភាពច្បាស់លាស់ មានភស្តុតាង និងឯកសារសំអាងគ្រប់គ្រាន់ទាំងអង្គហេតុ និងអង្គច្បាប់។ រាល់ពាក្យបណ្តឹងដែលបញ្ជូនទៅសមត្ថកិច្ចពាក់ព័ន្ធពិនិត្យដោះស្រាយ ត្រូវតាមដាន ស៊ើបសួរព័ត៌មានអំពីវឌ្ឍភាព នៃការដោះស្រាយឲ្យបានច្បាស់លាស់ និងទាន់ពេលវេលា រួចជូនព័ត៌មានទៅដើមបណ្តឹងវិញ។ ទង្វើនេះបង្ហាញពីការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋដែលជាអ្នកផ្តល់សេវាជូនប្រជាពលរដ្ឋ។

៥. មន្ត្រីរាជការក្រសួង ជាពិសេសមន្ត្រី ឬភ្នាក់ងារអធិការកិច្ចត្រូវស្វែងយល់អំពីច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធ និងការងារស្នូលរបស់ក្រសួង ដើម្បីមានលទ្ធភាព បកស្រាយ និងពន្យល់ពីការរកឃើញភាពអសកម្មនានា។

៦. វិទ្យាស្ថានជាតិអធិការកិច្ចត្រូវបង្កើត ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរៀបចំខ្លឹមសារកម្មវិធីបណ្តុះបណ្តាលថ្នាក់បឋម ថ្នាក់មធ្យម និងថ្នាក់ឧត្តម លើជំនាញអធិការកិច្ច និងជំនាញពាក់ព័ន្ធ។ វិទ្យាស្ថាន ក៏ត្រូវបណ្តុះបណ្តាលមុខជំនាញផ្សេងបន្ថែម ក្រៅពីអធិការកិច្ច ដូចជា ជំនាញអប់រំផ្សព្វផ្សាយច្បាប់ ជំនាញការសិក្សាស្រាវជ្រាវ ជំនាញវាយតម្លៃ ជំនាញផ្នែកស្ទាបស្ទង់មតិ និងជំនាញផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់របស់ក្រសួង។

៧. ត្រូវត្រៀមអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈព័ត៌មានវិទ្យា (FMIS) ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវធ្វើឲ្យបានហ្មត់ចត់ ច្បាស់លាស់ ជាពិសេសការប្រើប្រាស់កញ្ចប់ថវិកា ឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងសមស្របតាមបទដ្ឋានគតិយុត្ត។

៨. ក្នុងពេលបំពេញបេសកកម្មចុះធ្វើអធិការកិច្ច មន្ត្រី ឬភ្នាក់ងារអធិការកិច្ច ត្រូវគោរពឲ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់ នូវក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច ដែលបានដាក់ចេញរួចហើយ និង ត្រូវមានឯកសណ្ឋាន ដូចដែលក្រសួងបានណែនាំរួចហើយ និងត្រូវអនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ៖ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** ដែលយើងត្រូវចងចាំជានិច្ច។

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរ វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការ ក្រុមការងារនៃគណៈកម្មការរៀបចំសន្និបាត ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម និងដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើឱ្យសន្និបាតក្រសួងឆ្នាំនេះបានទទួលជោគជ័យគួរជាទីពេញចិត្ត។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

មុននឹងបញ្ចប់ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអបអរសាទរចំពោះលទ្ធផលដែលអង្គសន្និបាតសម្រេចបានក្នុងរយៈពេលពេញមួយថ្ងៃនេះ និងជឿជាក់យ៉ាងមុតមាំថា ឯកឧត្តម

លោកជំទាវ លោក លោកស្រីទាំងអស់នឹងបន្តអនុវត្តភារកិច្ច ដោយយកចិត្តទុកដាក់ខ្ពស់ បង្កើតបានសមិទ្ធផលថ្មីៗថែមទៀត ជូនរាជរដ្ឋាភិបាលដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍របស់ជាតិ។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ជាទីបញ្ចប់ ខ្ញុំ**សូមប្រកាសបិទសន្និបាត ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៨-២០១៩ចាប់ពីពេលនេះតទៅ។**

***សូមអរគុណ !***